Towards Sustainable Financial Management of Cambodian Universities

# របាយការណ៍

## ការណែនាំស្តីពីឧត្តមានុវត្តន៍សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ នៅតាមគ្រឹះស្ថានឧត្តមសិក្សា៖ សហភាពអឺរ៉ុប និងកម្ពុជា

Co-funded by the Erasmus+ Programme of the European Union

## គម្រោង

BALANCE – *"ឆ្ពោះទៅកាន់ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយចីរភាពនៃសាកលវិទ្យាល័យនៅកម្ពុជា"*

## លេខមូលនិធិ

# 598669-EPP-1-2018-1-ES-EPPKA2-CBHE-SP

## សមាគមរបស់

BALANCE

សាកលវិទ្យាល័យ អាលីកាន់តេ (University of Alicante)
សាកលវិទ្យាល័យ ហេងសំរិន ត្បូងឃ្មុំ
សាកលវិទ្យាល័យ ជាស៊ីម កំចាយមារ
សាកលវិទ្យាល័យ ស្វាយរៀង
សាកលវិទ្យាល័យ មានជ័យ
សាកលវិទ្យាល័យបាត់ដំបង
វិទ្យាស្ថានបច្ចេកវិទ្យា កំពង់ឈើទាល
វិទ្យាស្ថានបច្ចេកវិទ្យា កំពង់ស្ពឺ
សាកលវិទ្យាល័យភូមិន្ទកសិកម្ម
សាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ
សាកលវិទ្យាល័យ ជាតិគ្រប់គ្រង
វិទ្យាស្ថានជាតិអប់រំ
ក្រសួងអប់រំ យុវជន និងកីឡា

## ការជូនដំណឹងតាមផ្លូវច្បាប់

ឯកសារក្នុងពេលបច្ចុប្បន្ននេះ ត្រូវបានតាក់តែង និងកែសម្រួលដោយស្ថាប័នដៃគូនៃកម្មវិធី Erasmus+ នៃគម្រោង BALANCE – *"ឆ្ពោះទៅកាន់ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយចីរភាពនៃសាកលវិទ្យាល័យនៅកម្ពុជា"* ក្រោមការសម្របសម្រួលពីសាកលវិទ្យាល័យ អាលីកាន់តេ។ លទ្ធផល ទស្សនៈ និងគំនិតដែលសម្តែងចេញនៅក្នុងឯកសារ

បោះពុម្ពផ្សាយនេះ គឺជាលទ្ធផល ទស្សនៈ និងគំនិតរបស់អ្នកនិពន្ធ ហើយការិយាល័យបេសកកម្មសហភាពអឺរ៉ុប ពុំទទួលខុសត្រូវលើការប្រើប្រាស់ណាមួយ ដែលបានប្រើព័ត៌មានដែលមាននៅក្នុងឯកសារនេះឡើយ។

រាល់ខ្លឹមសារទាំងអស់ដែលបង្កើតឡើងតាមរយៈគម្រោង BALANCE នេះ ត្រូវបានការពារដោយច្បាប់កម្មសិទ្ធិបញ្ញា ក្នុងសិទ្ធិថតចម្លងពិសេស។

កែសម្រួលដោយ បណ្ឌិត រ៉ូប៊ឺតតូ អេស្ការ៉េ (Roberto Escarre) នៅសាកលវិទ្យាល័យអាលីកាន់តេ ប្រទេសអេស្ប៉ាញ

© Universidad de Alicante 2022. រក្សាសិទ្ធិគ្រប់យ៉ាង។
ការផលិតស្នាដៃនេះឡើយវិញ ត្រូវបានអនុញ្ញាត ប្រសិនបើមានការទទួលស្គាល់ប្រភពដើម។

សូមយោងឯកសារបោះពុម្ពផ្សាយនេះដូចតទៅ៖ *ការណែនាំស្តីពីឧត្តមានុវត្តន៍សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានឧត្តមសិក្សា៖ EU & Cambodia, 2022. BALANCE project. Erasmus+ programme.*

**ព័ត៌មានទំនាក់ទំនង៖**

ការិយាល័យគ្រប់គ្រងគម្រោងអន្តរជាតិ (OGPI) - សាកលវិទ្យាល័យ Alicante
គេហទំព័រ៖ www.ogpi.ua.es
គេហទំព័រគម្រោង BALANCE៖ www.balance-project.eu

# មាតិកា

បញ្ជីអក្សរកាត់ ..... ៤

១

សេចក្តីផ្តើម ..... ៥

២

ការណែនាំស្តីពីឧត្តមានុវត្តន៍ ..... ៧

២.១

ការគ្រប់គ្រងហិរញ្ញវត្ថុមានលក្ខណៈជាប្រព័ន្ធនាំទៅរកតម្លាភាព និងលទ្ធផលប្រកបដោយផលិតភាព ..... ១០

២.២

លើកកម្ពស់គុណភាពការអប់រំរបស់និស្សិតតាមរយៈការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់សាស្ត្រាចារ្យ ..... ១៥

២.៣

ការគ្រប់គ្រងហិរញ្ញវត្ថុ ប្រាក់រង្វាន់លើកទឹកចិត្ត និងផលិតភាព ..... ២២

២.៤

ការគ្រប់គ្រងហិរញ្ញវត្ថុដោយមានប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការលើកកម្ពស់ការជំរុញទឹកចិត្ត និងសកម្មភាពបំពេញការងារ ..... ២៩

២.៥

តួនាទី ទំនួលខុសត្រូវ ប្រតិភូកម្ម និងរចនាសម្ព័ន្ធនៃការធ្វើសេចក្តីសម្រេចចិត្តគ្រោងប្រាក់រង្វាន់លើកទឹកចិត្ត ..... ៣៥

៣

សេចក្តីសន្និដ្ឋាន ..... ៦៦

# បញ្ជីអក្សរកាត់

UA.......... សាកលវិទ្យាល័យអាលីកាន់តេ

UNIGE.... Universita degli Studi di Genova

UHST ..... សាកលវិទ្យាល័យ ហេង សំរិនត្បូងឃ្មុំ

CSUK..... សាកលវិទ្យាល័យ ជាស៊ីម កំចាយមារ

SRU ....... សាកលវិទ្យាល័យស្វាយរៀង

MCU....... សាកលវិទ្យាល័យមានជ័យ

UBB........ សាកលវិទ្យាល័យបាត់ដំបង

KCIT....... វិទ្យាស្ថានបច្ចេកវិទ្យា កំពង់ឈើទាល

KSIT....... វិទ្យាស្ថានបច្ចេកវិទ្យា កំពង់ស្ពឺ

RUA ....... សាកលវិទ្យាល័យភូមិន្ទកសិកម្ម

RUPP..... សាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ

NUM....... សាកលវិទ្យាល័យជាតិគ្រប់គ្រង

NIE......... វិទ្យាស្ថានជាតិអប់រំ

MoEYS... ក្រសួងអប់រំ យុវជន និងកីឡា

HE.......... ឧត្តមសិក្សា

HEIs....... គ្រឹះស្ថានឧត្តមសិក្សា

SEA........ អាស៊ីអាគ្នេយ៍

FM.......... ការគ្រប់គ្រងហិរញ្ញវត្ថុ

# ១

# សេចក្តីផ្តើម

# ១

# សេចក្តីផ្តើម

ការកសាងសមត្ថភាពនៅឧត្តមសិក្សានៃកម្មវិធី Erasmus+ នៃគម្រោង BALANCE – “ឆ្ពោះទៅកាន់ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយចីរភាពនៃសាកលវិទ្យាល័យនៅកម្ពុជា” បានចាប់ផ្តើមនៅក្នុងខែមករា ឆ្នាំ2019 ដែលមានគោលបំណងក្នុងការពង្រឹងស្វ័យភាពហិរញ្ញវត្ថុ និងគណនេយ្យភាពនៃគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសកម្ពុជា តាមរយៈការធ្វើទំនើបកម្មកលើការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ និងក្របខណ្ឌច្បាប់។

ក្នុងរយៈពេលជាង 3 ឆ្នាំ និងដោយមានកិច្ចសហការយ៉ាងសកម្មពីគ្រឹះស្ថានឧត្តមសិក្សារដ្ឋចំនួន 11 ក្នុងប្រទេសកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សាពីសហភាពអឺរ៉ុបចំនួន 2 គម្រោង BALANCE បានប្រមូលចងក្រងឧត្តមានុវត្តន៍ និងករណីសិក្សាអំពីគំនិតផ្តួចផ្តើមធ្វើទំនើបកម្ម ដែលបានសិក្សានៅសហភាពអឺរ៉ុប និងកម្ពុជា ដោយបានរួមចំណែកជាផ្លូវមួយដល់ការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសកម្ពុជា ដែលនឹងត្រូវបង្ហាញនៅក្នុងឯកសារនេះ។

លទ្ធផលរំពឹងទុក គឺដើម្បីលើកកម្ពស់នូវការយល់ដឹងអំពីការគ្រប់គ្រងហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានឧត្តមសិក្សា និងជំរុញឱ្យមានការផ្លាស់ប្តូរ តាមរយៈឧត្តមានុវត្តន៍នៅក្នុងប្រព័ន្ធឧត្តមសិក្សាកម្ពុជា។

# ២

# ការណែនាំស្ដីពីឧត្តមានុវត្តន៍

# ២

# ការណែនាំស្តីពីឧត្តមានុវត្តន៍

តាមរយៈការរួមបញ្ចូលគ្នានូវលទ្ធផលពីសកម្មភាពពីមុនៗ ជាពិសេសរបាយការណ៍ស្តីពីគំរូហិរញ្ញវត្ថុកម្ពុជា (D1.1.1) និងរបាយការណ៍ស្តីពីគំរូហិរញ្ញវត្ថុសហភាពអឺរ៉ុប (D1.2.2) ក៏កំណត់បានជាឧត្តមានុវត្តន៍នៃគំនិតផ្តួចផ្តើមទំនើបកម្មដែលធ្វើឡើងនៅក្នុងសហភាពអឺរ៉ុប និងប្រទេសកម្ពុជា។ ឧត្តមានុវត្តន៍ទាំងនេះ ត្រូវបានប្រើប្រាស់ក្នុងពេលថ្មីៗនេះ ជាឧទាហរណ៍ក្នុងអំឡុង WP (កញ្ចប់ការងារ) 2 និង WP3 នៅពេលដែលដៃគូទទួលស្គាល់នូវកិច្ចការមួយចំនួន (2.1 ការបង្កើតផែនការបណ្តុះបណ្តាល និងធនធានសិក្សា) 2.2 ការធ្វើទំនើបកម្ម និងការពង្រឹងសមត្ថភាពមនុស្ស 2.3 សិក្ខាសាលានៅកម្រិតគ្រឹះស្ថាន 3.1 ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធ IT នៅតាមអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ និង 3.2 ការបង្កើតផែនការសកម្មភាពគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ឆ្នាំ 2020-2024) ដែលមានគោលដៅក្នុងការរួមចំណែកដល់ការធ្វើទំនើបកម្មនៃអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ។

ឧត្តមានុវត្តន៍នេះ ដែលបានបង្ហាញនូវក្នុងផ្នែកនេះ គឺត្រូវបានរៀបចំឡើងជា 5 ប្រភេទ៖

- ការគ្រប់គ្រងហិរញ្ញវត្ថុមានលក្ខណៈជាប្រព័ន្ធ នាំទៅរកតម្លាភាព និងលទ្ធផលប្រកបដោយផលិតភាព៖ ករណីសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ
- លើកកម្ពស់គុណភាពការអប់រំរបស់និស្សិតតាមរយៈការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់សាស្ត្រាចារ្យ៖ សម្រាប់ករណីវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល និងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ
- ការគ្រប់គ្រងហិរញ្ញវត្ថុ ប្រាក់រង្វាន់លើកទឹកចិត្ត និងផលិតភាព៖ ករណីវិទ្យាស្ថានជាតិអប់រំ សាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ
- ការគ្រប់គ្រងហិរញ្ញវត្ថុដោយមានប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការលើកកម្ពស់ការជំរុញទឹកចិត្ត និងសកម្មភាពបំពេញការងារ ករណី NMU, NUBB, សាកលវិទ្យាល័យស្វាយរៀង និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- តួនាទី ទំនួលខុសត្រូវ ប្រតិភូកម្ម និងរចនាសម្ព័ន្ធនៃការធ្វើសេចក្តីសម្រេចចិត្ត, គ្រោងប្រាក់រង្វាន់លើកទឹកចិត្ត៖ ករណីសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ

# សាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ

# ១

# សាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ

## ការគ្រប់គ្រងហិរញ្ញវត្ថុមានលក្ខណៈជាប្រព័ន្ធ នាំទៅកេតម្លាភាព និងលទ្ធផលប្រកបដោយផលិតភាពៈ ករណីសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ

### ១.១. សាវតា

សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ (សជជក) បានផ្លាស់ប្តូរឈ្មោះពីសាកលវិទ្យាល័យវេទមហាឫស្សី (សវម) ក្នុងឆ្នាំ ២០០៨។ ទីតាំងសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ មានទីតាំងស្ថិតក្នុងស្រុកកំចាយមារក្នុងខេត្តព្រៃវែងចម្ងាយប្រហែល108គមភាគខាងកើតរាជធានីភ្នំពេញ។សាកលវិទ្យាល័យនេះផ្តល់ការអប់រំដល់យុវជននៅតាមស្រុកស្រែចំការដែលមិនមានឱកាសទទួលបានការសិក្សានៅថ្នាក់ឧត្តមសិក្សា។ សាកលវិទ្យាល័យក៏បានខិតខំបណ្តុះបណ្តាលអ្នកដឹកនាំថ្មីជំនាន់ក្រោយ ដោយគ្មានសម្ពាធនិងបន្ទុកនៃប្រវត្តិសាស្ត្របច្ចុប្បន្នរបស់ប្រទេសកម្ពុជា។ សជជក គឺជាគ្រឹះស្ថានឧត្តមសិក្សាមួយដែលគ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡានៃរាជរដ្ឋាភិបាលកម្ពុជា។ បច្ចុប្បន្ននេះ សជជក មានមហាវិទ្យាល័យចំនួន 5 រួមមាន មហាវិទ្យាល័យគ្រប់គ្រង មហាវិទ្យាល័យសិល្បៈ មហាវិទ្យាល័យមនុស្សសាស្ត្រ មហាវិទ្យាល័យភាសាបរទេស មហាវិទ្យាល័យសង្គមសាស្ត្រ មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងមហាវិទ្យាល័យកសិកម្ម។

មកទល់នឹងពេលសព្វថ្ងៃនេះ សជជក មាននិស្សិតបញ្ចប់ការសិក្សាប្រមាណ 3,500 នាក់ ដែលទទួលបានការងារធ្វើនៅក្នុងផ្នែកសេវាសាធារណៈ វិស័យឯកជន និងអង្គការជាតិ និងអង្គការអន្តរជាតិ។ ភាគច្រើននៃនិស្សិតបញ្ចប់ការសិក្សានេះ បានការចុះឈ្មោះសិក្សាកម្មវិធីសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត មានអ្នកខ្លះបានទទួលអាហារូបករណ៍ទៅសិក្សាថ្នាក់ក្រោយឧត្តមសិក្សានៅក្រៅប្រទេសទៀតផង។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ មាននិស្សិតប្រមាណ 5,500 នាក់ បានចុះឈ្មោះចូលរៀនក្នុងកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រនៅ សជជម។

សជជម មានចក្ខុវិស័យក្នុងការក្លាយខ្លួនជាសាកលវិទ្យាល័យឈានមុខគេក្នុងផ្នែកសិក្សារៀនសូត្រ បង្រៀន និងស្រាវជ្រាវក្នុងតំបន់ភាគខាងកើតប្រទេស ដែលមានធនធានមនុស្ស

ដែលមានគុណភាព ចំណេះដឹង នវានុវត្តន៍ និងកាលានុវត្តភាព ដើម្បីចូលរួមក្នុងការអភិវឌ្ឍសង្គមជាតិ និងកសាងសង្គមមួយប្រកបដោយចីរភាព។

ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុនេះ សាកលវិទ្យាល័យមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមួយ។ សជជម មានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធគ្រប់គ្រងដែលដឹកនាំដោយប្រធានមួយរូប ដែលមានទំនួលខុសត្រូវច្បាស់លាស់ ក៏ដូចជាមានផែនការថវិកាមួយ ដើម្បីបំពេញតាមប្រតិបត្តិការ និងការចំណាយលើទ្រព្យមូលធនផងដែរ។ បន្ថែមលើនេះ ក៏មានគណៈកម្មការធានាអាប់រងគុណភាព និងសវនកម្មផ្ទៃក្នុងផងដែរ ដែលតែងធ្វើការត្រួតពិនិត្យឆ្លងរាល់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងហិរញ្ញវត្ថុ។
តាមរយៈអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ សជជម កំពុងទទួលបានការទទួលស្គាល់ពី "ឧត្តមានុវត្តន៍" ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ដែលមានចំណងជើងថា "*ការគ្រប់គ្រងហិរញ្ញវត្ថុមានលក្ខណៈជាប្រព័ន្ធ នាំទៅរកតម្លាភាព និងលទ្ធផលប្រកបដោយផលិតភាព*"

## ១.២. ព័ត៌មានលម្អិតអំពីឧត្តមានុវត្តន៍

ខាងក្រោមនេះគឺជាបណ្តុំព័ត៌មានលម្អិតពាក់ព័ន្ធនឹងឧត្តមានុវត្តន៍ ដែល សជជម បានអនុវត្ត។

### ១.២.១.ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ

សជជម មានប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុលក្ខណៈជាប្រព័ន្ធ និងគោលនយោបាយច្បាស់លាស់ (ដែលមានការណែនាំតាមដំណាក់កាល)។ជាងនេះទៅទៀត យើងបានរក្សាទុកព័ត៌មានទាំងអស់ដែលពាក់ព័ន្ធបញ្ហាហិរញ្ញវត្ថុក្នុងម៉ាស៊ីនមេដែលមានសមត្ថភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុទទួលបានជំនួយហិរញ្ញវត្ថុពីគម្រោង BALANCE។

### ១.២.២. តម្លាភាព

តាមរយៈម៉ាស៊ីនមេ និងរបាយការណ៍ធនាគារ (ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ) រាល់ចំណូល ចំណាយ និងបញ្ហាពាក់ព័ន្ធនឹងហិរញ្ញវត្ថុផ្សេងទៀតទាំងអស់ អាចធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងផ្សព្វផ្សាយនៅពេលចាំបាច់ ឬនៅពេលធ្វើសវនកម្ម។ ប្រព័ន្ធនេះបាននាំទៅរកនីតិវិធីដែលមានតម្លាភាពនៅក្នុង សជជម។ រាល់ប្រតិបត្តិការទាំងអស់ដែលបានតាមដាន ក៏ផ្តល់ជូនសូចនាករល្អ ដើម្បីបង្កើតការធ្វើផែនការហិរញ្ញវត្ថុសម្រាប់ពេលរាប់សិបឆ្នាំផងដែរ។

### ១.២.៣. ផលិតភាព

ដោយសារប្រព័ន្ធ និងឧបករណ៍ដែលបានផ្តល់ដោយគម្រោង BALANCE ក្រុមអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុរបស់យើង អាចធ្វើការកាន់តែមានប្រសិទ្ធភាព និងផលិតភាព។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសន្សំសំចៃពេលវេលា ហើយមានលក្ខណៈជាប្រព័ន្ធ និងបង្កកំហុសតិចតួចជាងមុន។ តាមរយៈមេរៀនដែលបានរៀនសូត្រពីការបណ្តុះបណ្តាលដែលធ្វើឡើងដោយដៃគូសហភាពអឺរ៉ុប បុគ្គលិករបស់យើងក៏អាចធ្វើការបានល្អប្រសើរជាងមុនផងដែរ។

### ១.២.៤. ការធ្វើទំនើបកម្ម

បុគ្គលិកនិងនិស្សិតនៃ សជជម ទទួលបានការបណ្តុះបណ្តាលពីរបៀបប្រើប្រាស់ធនាគារ។ កាលពីមុនមធ្យោបាយបង់ប្រាក់ដែលអនុញ្ញាតនៅសាកលវិទ្យាល័យ ជាមធ្យោបាយចាស់ ដូចជាការប្រើប្រាស់តែសាច់ប្រាក់ ឬប្រាក់វេផ្ទេរទេយ្យតែប៉ុណ្ណោះ ប៉ុន្តែការធ្វើទំនើបកម្មនេះ បានជួយកែលម្អបទប្បញ្ញត្តិរបស់ពួកគេមួយកម្រិត។ គ្រប់សិស្សទាំងអស់ ត្រូវបានតម្រូវឱ្យបង់ថ្លៃសិក្សារបស់ពួកគេតាមរយៈការដាក់ប្រាក់ចូលទៅក្នុងគណនីធនាគារ។

## ១.៣. តស្តុតាងនៃភាពជោគជ័យ (លទ្ធផលដែលសម្រេចបាន)

### ១.៣.១. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ

យើងបានដំឡើងម៉ាស៊ីនមេ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនៅ សជជម រួចហើយ ហើយពេលនេះ អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុកំពុងប្រើប្រាស់វា។ ប្រព័ន្ធនេះត្រូវប្រើដើម្បីបង់ថ្លៃប្រាក់ឈ្នួលសាស្ត្រាចារ្យ ក៏ដូចជាដើម្បីអនុលោមតាមគោលនយោបាយនេះផងដែរ (ឧ.ទា. សាស្ត្រាចារ្យដែលមានសញ្ញាបត្របណ្ឌិតដែលបង្រៀនកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ គឺត្រូវទទួលបានប្រាក់ឈ្នួលរហូតដល់ 800$/វគ្គសិក្សាដែលមាន 3 ក្រេឌីត ចំណែកឯសាស្ត្រាចារ្យដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ត្រូវទទួលបានប្រាក់ឈ្នួលរហូតដល់ 600$/វគ្គសិក្សាដែលមាន 3 ក្រេឌីត) និងសម្រាប់ការបង់ថ្លៃសិក្សា។

### ១.៣.២. តម្លាភាព

រាល់ឯកសារដែលពាក់ព័ន្ធនឹងហិរញ្ញវត្ថុត្រូវបញ្ចេញទាំងស្រុង សម្រាប់ការធ្វើសវនកម្មពាក់កណ្តាលឆ្នាំ និងសវនកម្មប្រចាំឆ្នាំ។ ប្រតិបត្តិការហិរញ្ញវត្ថុរបស់ សជជម មានកម្រិតនៃការប៉ាន់ស្មានថវិកាសម្រាប់ការចំណាយទាប។

### ១.៣.៣. ផលិតភាព

យើងធ្វើរបាយការណ៍ និងអនុវត្តដំណើរការទាន់ពេលវេលា ដែលអនុវត្តទៅតាមការធ្វើផែនការ ។ នេះគឺដោយសារយើងមានគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុល្អ និងច្បាស់លាស់។

### ១.៣.៤. ការធ្វើទំនើបកម្ម

ភាគច្រើនលើសលប់នៃបុគ្គលិកនិងនិស្សិតនៃ សជជម អាចដេញតាមទាន់យុគសម័យឧស្សាហកម្ម 4.0 តាមរយៈការប្រើប្រាស់សេវាធនាគារឌីជីថល។

### ១.៣.៥. បុគ្គលិកដែលគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ

ប្រធាននិងអនុប្រធានផ្នែកប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ទទួលបានការបណ្តុះបណ្តាលយ៉ាងល្អតាមរយៈការផ្តល់ជូនមូលដ្ឋានរឹងមាំ (ពាក់ព័ន្ធនឹងប្រតិបត្តិការប្រព័ន្ធ) ដើម្បីប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុហើយពេលនេះពួកគេបានក្លាយជាអ្នកជំនាញក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនេះ។ ដើម្បីអនុលោមទៅតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ សជជម ប្រធាននិងអនុប្រធាននៃអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ បានផ្តល់ការបណ្តុះបណ្តាលជាប្រចាំ ដល់

បុគ្គលិកដែលជាប់ពាក់ព័ន្ធនឹងខាងហិរញ្ញវត្ថុ រួមបញ្ចូលទាំងអ្នកដែលមកពីការិយាល័យច្បាប់ពីខាងមហាវិទ្យាល័យនិងគ្រឹះស្ថាននីមួយៗផង។

## ១.៣.៦. បរិស្ថាន និងគោលនយោបាយ

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុត្រូវត្រួតពិនិត្យដោយសាកលវិទ្យាធិការ និងត្រូវធ្វើគ្រប់គ្រងតាមដានយ៉ាងតឹងរឹង ធ្វើការត្រួតពិនិត្យឆ្លង និងធ្វើសវនកម្មផ្ទៃក្នុងដោយសាកលវិទ្យាធិការរងដែលទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ។ ស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ពីសាកលវិទ្យាធិការរង ប្រធាននិងអនុប្រធាននៃអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រតិបត្តិការហិរញ្ញវត្ថុសំខាន់ៗ។ រាល់ការធ្វើផែនការហិរញ្ញវត្ថុទាំងអស់ ត្រូវធ្វើផែនការរួមគ្នា និងបង្កើតឡើងរួមគ្នាដោយគណៈគ្រប់គ្រង ក្រុមគ្រប់គ្រង (សាកលវិទ្យាធិការនិងសាកលវិទ្យាធិការរង នាយក និងនាយករង) និងប្រធាននិងអនុប្រធានអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ។ ប្រតិបត្តិការថវិកាតិច (< 500USD) អាចអនុម័តដោយអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុបាន។ បើពុំដូច្នោះទេ ត្រូវឱ្យសាកលវិទ្យាធិការរង/សាកលវិទ្យាធិការបានពិនិត្យ និងឯកភាព។ រាល់ប្រតិបត្តិការ និងគោលការណ៍ណែនាំទាំងនេះ ត្រូវអនុលោមទៅតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសាកលវិទ្យាល័យជាស៊ីមកំចាយមារដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។

## ១.៤. សក្តានុពលសម្រាប់ការរៀនសូត្រ ឬការផ្ទេរបន្ត

ក. សក្តានុពលសម្រាប់ការរៀនសូត្រ៖ ប្រភពប្រាក់ចំណូល (ការបង្កើតប្រាក់ចំណូល) និងយុទ្ធសាស្ត្រគ្រប់គ្រងហិរញ្ញវត្ថុ ដែលបានរៀនសូត្រពីដៃគូសហភាពអឺរ៉ុប។

ខ. សក្តានុពលសម្រាប់ការផ្ទេរបន្ត៖ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ គោលនយោបាយ និងការធ្វើទំនើបកម្ម អាចផ្ទេរទៅកាន់បណ្តាសាកលវិទ្យាល័យនៅកម្ពុជាបាន។

## ១.៥. ព័ត៌មានបន្ថែម

សជជម កំពុងកែលម្អវិធីដែលខ្លួនទទួលបានធនធានប្រាក់ចំណូល និងរបៀបដែលខ្លួនបង្កើតប្រាក់ចំណូលបន្ថែម ក្រៅពីតាមរយៈថ្លៃសិក្សារបស់និស្សិត ដោយធ្វើការបង្កើតវេទិកាសេវាករ (ឧ.ទា. ផលិតផលកសិកម្ម ការដំឡើងហេដ្ឋារចនាសម្ព័ន្ធ IT ។ល។)

## ១.៦. ព័ត៌មានលម្អិតទំនាក់ទំនង

**សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ**

អាសយដ្ឋាន៖ ផ្លូវជាតិលេខ ៨ ភូមិថ្នល់កែង ស្រុកកំចាយមារ ខេត្តព្រៃវែង ប្រទេសកម្ពុជា

**អង្គភាពធ្វើផែនការគ្រប់គ្រងហិរញ្ញវត្ថុនៃ សជជម ក្នុងគម្រោង BALANCE**

លោក សុក រ៉ាឌី សាកលវិទ្យាធិការរង លេខទូរសព្ទ៖

(+855) 78 86 66 67

អ៊ីម៉ែល៖ radys.fdcc@yahoo.com

គេហទំព័រ៖ http://www.csuk.edu.kh

# វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល

## ( វ.ប.ក.ឈ )

# ២
# វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល (វ.ប.ក.ឈ)

## លើកកម្ពស់គុណភាពការអប់រំរបស់និស្សិតតាមរយៈការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់សាស្ត្រាចារ្យ

### ២.១. សាវតារ

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល (វ.ប.ក.ឈ) គឺជាគ្រឹះស្ថានឧត្តមសិក្សារដ្ឋមួយ ដែលត្រូវបានបង្កើតឡើងដោយព្រះអង្គម្ចាស់ក្សត្រិយ៍មហាចក្រីសិរិនថននៃប្រទេសថៃ ដោយមានកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែលមានទីតាំងនៅភូមិសំបួរ ឃុំសំបួរ ស្រុកសំបួរ ខេត្តកំពង់ធំ ព្រះរាជាណាចក្រកម្ពុជា ដែលមានផ្ទៃដែលសរុបចំនួន 21 ហិចតា។ ចំពោះទីតាំងនេះត្រូវបានពង្រីកបន្ថែមពីលើទីតាំងចាស់របស់វិទ្យាល័យកំពង់ឈើទាល ដោយអនុក្រឹត្យលេខ 46 អនក្រ.បក ចុះថ្ងៃទី7 ខែមេសា ឆ្នាំ2015។

វ.ប.ក.ឈ ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជំនាញបច្ចេកទេសឯកទេស និងក្រមសីលធម៌វិជ្ជាជីវៈ ជាការឆ្លើយតបនឹងទីផ្សារការងាររដ្ឋនិងឯកជន ដើម្បីចូលរួមក្នុងការកសាងនិងអភិវឌ្ឍន៍ជាតិ។ វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល (វ.ប.ក.ឈ) គឺជាគ្រឹះស្ថានឧត្តមសិក្សារដ្ឋមួយ ដែលផ្តោតសំខាន់លើផ្នែកកសិកម្ម និងបច្ចេកវិទ្យាឧស្សាហកម្ម ដែលផ្តល់នូវការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង (វិទ្យាសាស្ត្រសត្វ វិទ្យាសាស្ត្រដំណាំ ថាមពលអេឡិចត្រូនិក ទេសចរណ៍ និងគ្រប់គ្រងសណ្ឋាគារ បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន (ICT) អេឡិចត្រូនិក) បរិញ្ញាបត្រ (វិទ្យាសាស្ត្រសត្វ វិទ្យាសាស្ត្រដំណាំ ថាមពលអេឡិចត្រូនិក) និងសញ្ញាបត្រគរុកោសល្យ (អេឡិចត្រូនិក និង ICT ការចិញ្ចឹមសត្វ និងកសិកម្ម អគ្គិសនី និងជំនាញបច្ចេកទេសរោងជាងកម្រិតមូលដ្ឋាន)។

វ.ប.ក.ឈ បានបង្កើនផែនការយុទ្ធសាស្ត្រផ្ទាល់ខ្លួន ដែលជាផែនទីបង្ហាញផ្លូវមួយ ដើម្បីព្យាយាមនិងសម្រេចឱ្យបាននូវចក្ខុវិស័យ "ដើម្បីក្លាយខ្លួនជាវិទ្យាសាស្ត្របច្ចេកទេសឈានមុខគេមួយ ដោយបណ្តុះបណ្តាលពលរដ្ឋឱ្យមានសមត្ថភាពខ្ពស់ និងមានជំនាញវិជ្ជាជីវៈសម្រាប់ការអភិវឌ្ឍជាតិ និងដើម្បីសម្រេចនូវបេសកកម្ម៖ ផ្តល់ការបណ្តុះបណ្តាលនៅក្នុងកម្មវិធីសិក្សា ថ្នាក់វិទ្យាល័យ

កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្ររង ក៏ដូចជាកម្មវិធីបំណិនជីវិត និងកម្មវិធីគ្រូបង្រៀនបច្ចេកទេសនៅក្នុងមុខវិជ្ជាឧស្សាហកម្មនិងកសិកម្មផងដែរ។ ដោយផ្តល់ការបណ្តុះបណ្តាលតាមសេវាកម្មសម្រាប់ការលើកកម្ពស់សមត្ថភាពការបង្រៀន ពាក់ព័ន្ធនឹងបំណិនជីវិត និងការបង្រៀនបច្ចេកទេស ការស្រាវជ្រាវ និងការបង្កើតបច្ចេកវិទ្យាថ្មីសមស្រប និងនវានុវត្តន៍សម្រាប់ឧស្សាហកម្ម និងកសិកម្ម ផ្តល់សេវា TVET ដល់សហគមន៍ និងអភិវឌ្ឍចំណេះដឹង វប្បធម៌ និងបរិស្ថានក្នុងមូលដ្ឋានតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា។

បច្ចុប្បន្ននេះ មានបុគ្គលិកចំនួន 128 រូប បម្រើការជាបុគ្គលិករដ្ឋបាលបុគ្គលិកការិយាល័យ និងបុគ្គលិកសិក្សា ហើយមាននិស្សិតអាហារូបករណ៍ 100% ចំនួន 178 នាក់ ដែលបានចុះឈ្មោះចូលរៀននៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រដំណាំ វិទ្យាសាស្ត្រសត្វ អេឡិចត្រូនិកថាមពលអគ្គិសនី ទេសចរណ៍ និងការគ្រប់គ្រងសណ្ឋាគារ បច្ចេកទេសរោងជាងកម្រិតមូលដ្ឋាន ការចិញ្ចឹមសត្វនិងកសិកម្ម។ បន្ថែមលើនេះ មាននិស្សិតចំនួន 1,049 នាក់ បានចុះឈ្មោះចូលរៀនក្នុងគ្រឹះស្ថាននេះនៅកម្រិតសិក្សាថ្នាក់វិទ្យាល័យ។

## ២.២. ព័ត៌មានលម្អិតអំពីឧត្តមានុវត្តន៍

តាមរយៈបទពិសោធដែលទទួលបាននៅក្នុងការចូលរួមសិក្ខាសាលា និងតាមរយៈទស្សនៈកិច្ចសិក្សានៃគម្រោង BALANCE និងកិច្ចប្រជុំនៅក្នុងរយៈពេលនៃគម្រោងនេះទាំងមូល ការិយាល័យហិរញ្ញវត្ថុរបស់ វ.ប.ក.ឈ បានតួនាទីយ៉ាងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងកញ្ចប់ថវិការបស់វិទ្យាស្ថាន ដើម្បីបើកប្រាក់ និងគាំទ្រដល់ដំណើរការនៃការបង្រៀន និងការរៀនសូត្រនៃមហាវិទ្យាល័យនីមួយៗ ដើម្បីបង្កើនចំនួនសិស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលធ្វើការនៅក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម និងបម្រើដល់សង្គមជាតិផងដែរ។ នៅក្នុងឆ្នាំនេះ វ.ប.ក.ឈ បានធ្វើការពិនិត្យឡើងវិញលើផែនការយុទ្ធសាស្ត្រថវិការយៈពេល 3 ឆ្នាំ (2022-2024) ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តកញ្ចប់ថវិកាសម្រាប់ការពង្រឹងនីតិវិធីរៀបចំវិទ្យាសាស្ត្រ។ ថវិកាប្រចាំឆ្នាំត្រូវបានប្រើសម្រាប់ការកសាងសមត្ថភាពបុគ្គលិករដ្ឋបាលនិងបុគ្គលិកបង្រៀន ការរៀបបន្ទប់រៀន និងសួនច្បារ កម្មវិធីសិក្សា សៀវភៅពុម្ព និងការបង្កើតសម្ភារៈឧបទេស ក៏ដូចជាការផ្តល់ជំនាញបណ្តុះបណ្តាលបច្ចេកទេសដល់បុគ្គលិកបង្រៀនផងដែរ ទាំងនៅក្នុងស្រុក និងនៅក្រៅស្រុក។ ហេតុនេះ គោលបំណងសំខាន់នៃការផ្តល់ថវិកាប្រចាំឆ្នាំនេះ គឺត្រូវផ្តោតសំខាន់លើប្រតិបត្តិការរៀបចំ ការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងគុណភាពនៃការបង្រៀន និងការរៀនសូត្រ។

**បណ្តុំសកម្មភាពទីមួយ៖ ការិយាល័យហិរញ្ញវត្ថុ បានផ្តល់ថវិកាប្រចាំឆ្នាំដើម្បីគាំទ្រដល់គុណភាព សមភាព និងបរិយាបន្ន ដើម្បីលើកកម្ពស់ការសិក្សាពេញមួយជីវិតរបស់សម្រាប់និស្សិត៖**

- គាំទ្រដល់ការគ្រប់គ្រងតាមដាន និងការវាយតម្លៃដំណើរការរបស់វិទ្យាស្ថាន។
- បង្កើនចំនួនសិស្សដែលចុះឈ្មោះនៅក្នុងផ្នែកបច្ចេកវិទ្យា ដែលបានគិតគូរពីសមភាព បរិយាបន្ន និងស្របទៅតាមតម្រូវការរបស់ជាតិ។
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទាំងជាមួយដៃគូពីវិស័យរដ្ឋ និងវិស័យឯកជន ទាំងក្នុងស្រុកនិងក្រៅស្រុក ដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀន និងការរៀនសូត្រ ក៏ដូចជាគម្រោងស្រាវជ្រាវ និងសេវាសហគមន៍ផងដែរ។

**បណ្តុំសកម្មភាពទីពីរៈ ការិយាល័យហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវដំណើរការនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៅគ្រប់អង្គភាពទាំងអស់ក្នុងវិទ្យាស្ថានៈ**
- ថវិកាដែលបានផ្តល់ជូនបន្ថែមសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងការពង្រឹងគុណវុឌ្ឍិរបស់បុគ្គលិកមហាវិទ្យាល័យ។
- ការចំណាយលើសិក្ខាសាលា និងសិក្ខាសាលាបណ្តុះបណ្តាល ដើម្បីជំរុញការលើកទឹកចិត្តការងារ និងប្រសិទ្ធភាព ។ល។

## ២.៣. តស្តុតាងនៃភាពជោគជ័យ (លទ្ធផលដែលសម្រេចបាន)

**វឌ្ឍនភាពដែលបានធ្វើឡើងតាមរយៈការអនុវត្តការធ្វើកំណែទម្រង់ក្នុងឆ្នាំ2020**

### ២.៣.១. យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងការអប់រំ

**ក. កំណែទម្រង់ការគ្រប់គ្រងសិក្សាធិការ**

វិទ្យាស្ថាននេះបានអនុវត្តកិច្ចការនេះស្របទៅតាមគោលការណ៍និងការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយផ្តោតសំខាន់លើគុណភាពនៃការអប់រំនិងការបណ្តុះបណ្តាល សមភាព បរិយាប័ន្ន និងការសិក្សាពេញមួយជីវិតសម្រាប់មនុស្សគ្រប់គ្នា។ ហេតុដូចនេះហើយនេះ វិទ្យាស្ថានបានចំណាយថវិកាប្រចាំឆ្នាំភាគច្រើនក្នុងការធ្វើកំណែទម្រង់ការគ្រប់គ្រងការអប់រំ រួមមានជាអាទិ៍ៈ
- ការកែសម្រួលកម្មវិធីសិក្សា និងម៉ោងបង្រៀន ស្របតាមតម្រូវការជាក់ស្តែង។
- ការរៀបចំ និងការចងក្រងសៀវភៅពុម្ពបច្ចេកទេស ស្របតាមតម្រូវការរបស់និស្សិត និងសាស្ត្រាចារ្យ។
- ការលើកកម្ពស់វិធីសាស្ត្រក្នុងការបង្រៀន។ មានកិច្ចប្រជុំបច្ចេកទេសក្នុងការផ្លាស់ប្តូរបទពិសោធក្នុងវិធីបង្រៀនជារៀងរាល់ខែ។
- ការផ្តល់ថវិកាដើម្បីទិញឧបករណ៍ដែលចាំបាច់សម្រាប់ការបង្កើតសម្ភារៈដែលមានតម្លៃសមរម្យនិងគ្រប់គ្រាន់នៅក្នុងដំណើរការនៃការបង្រៀននិងការរៀន។
- ការបង្កើតសម្ភារៈបច្ចេកទេសសម្រាប់ការបង្រៀននិងការរៀន និងមន្ទីរពិសោធន៍ឆ្លើយតបទៅនឹងការអភិវឌ្ឍបច្ចេកទេសជាសកល។
- ការរៀបចំ ការអាន និងការស្រាវជ្រាវឯកសារ និងឧបករណ៍បច្ចេកវិទ្យាព័ត៌មាន ដូចជា

សៀវភៅ កុំព្យូទ័រថ្មី អ៊ីនធឺណិតល្បឿនលឿន ។ល។ សម្រាប់បណ្ណាល័យ ដើម្បីជំរុញឱ្យនិស្សិតអាន និងស្រាវជ្រាវនៅក្នុងបណ្ណាល័យ។

- បណ្តុះបណ្តាលសិស្សនៅក្នុងការវិភាគ ការដោះស្រាយបញ្ហា និងការធ្វើការងារជាក្រុម ដោយផ្តោតសំខាន់លើអត្ថប្រយោជន៍នៃការរៀនសូត្រ។ ប្រព័ន្ធប្រាក់រង្វាន់លើកទឹកចិត្ត និងការដាក់ពិន័យ ក៏ត្រូវបានបង្កើតឡើងសម្រាប់បុគ្គលិក និស្សិត និងសាស្ត្រាចារ្យផងដែរ។

**ខ. កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល**

ការិយាល័យហិរញ្ញវត្ថុ បានផ្តល់ប្រាក់ប្រមាណ 20% នៃថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន ដើម្បីគាំទ្រដល់ការគ្រប់គ្រងរដ្ឋបាល ដើម្បីធានានូវប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការសម្របសម្រួលដល់កិច្ចការអេចិន្ត្រៃយ៍របស់វិទ្យាស្ថាន។ ការគ្រប់គ្រងរដ្ឋបាល បានចំណាយថវិកាភាគច្រើនលើ៖

- ការរៀបចំកិច្ចប្រជុំដើម្បីលើកកម្ពស់តួនាទីនិងទំនួលខុសត្រូវរបស់បុគ្គលិកគាំទ្រឱ្យបានត្រឹមត្រូវ ដោយរៀបចំឯកសារផ្លូវច្បាប់ស្របតាមនីតិវិធីរដ្ឋបាល។
- អនុញ្ញាតនិងលើកទឹកចិត្តអាជ្ញាធរមូលដ្ឋាន និងសហគមន៍ឱ្យចូលរួមក្នុងសកម្មភាពគ្រប់គ្រងរបស់វិទ្យាស្ថាន។
- បង្កើតមជ្ឈដ្ឋានការងារមួយ ដើម្បីបង្កើនទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការ។
- គ្រប់គ្រងតាមដានវត្តមានម៉ោងចូលនិងម៉ោងចេញរបស់បុគ្គលិកសិក្សា។
- បង្កើតប្រព័ន្ធប្រាក់រង្វាន់លើកទឹកចិត្ត និងការដាក់ពិន័យសម្រាប់បុគ្គលិកគាំទ្រ។

**គ. កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ**

ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិទ្យាស្ថាននេះបានធ្វើការយកចិត្តទុកដាក់លើតម្រូវការក្នុងការបញ្ជូនបុគ្គលិកការិយាល័យហិរញ្ញវត្ថុឱ្យទៅចូលរួមក្នុងការសិក្ខាសាលាបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗ ដើម្បីពង្រឹងសមត្ថភាព និងជំនាញក្នុងការការគ្រប់គ្រងថវិកា និងផែនការនានា។ វិទ្យាស្ថានក៏បានផ្តោតសំខាន់លើការបណ្តុះបណ្តាលពីនីតិវិធីនៃការផ្តល់ថវិកាកម្មវិធី (PB) និងការលើកទឹកចិត្តបុគ្គលិកការិយាល័យហិរញ្ញវត្ថុឱ្យធ្វើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP) ថវិកាប្រចាំឆ្នាំ ផែនការប្រតិបត្តិប្រចាំឆ្នាំ (AOP) និងផែនការសកម្មភាពដទៃផ្សេងទៀត ដើម្បីប្រើប្រាស់ថវិកាឱ្យមានប្រសិទ្ធភាព ដើម្បីសម្រេចលទ្ធផលស្របតាមកម្មវត្ថុដែលវិទ្យាស្ថានបានកំណត់។ ការធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបានអនុវត្តដូចខាងក្រោម៖

- រៀបចំតាក់តែង កែតម្រូវ និងកែលម្អតួនាទីនិងទំនួលខុសត្រូវរបស់មន្ត្រីហិរញ្ញវត្ថុ។
- ត្រួតពិនិត្យការអនុវត្តថវិកា និងការទូទាត់នៃថវិកាកម្មវិធីសម្រាប់ឆ្នាំ2020។
- ធ្វើការត្រួតពិនិត្យការអនុម័តថវិកាដែលបានស្នើសុំឱ្យបានហ្មត់ចត់។
- ធ្វើផែនការថវិកាយុទ្ធសាស្ត្រ ធ្វើការត្រួតពិនិត្យ លើកកម្ពស់ និងកែលម្អផែនការប្រតិបត្តិប្រចាំ

ឆ្នាំ។
- ការបង្កើតយន្តការ និងគណៈកម្មការចំណាយ ដើម្បីធ្វើការវាយតម្លៃការចំណាយថវិកាឱ្យបានត្រឹមត្រូវ។
- បង្កើនតម្លាភាពនៅក្នុងការអនុវត្តថវិកា។

**ឃ. កំណែទម្រង់ការគ្រប់គ្រងធនធាន**

វិទ្យាស្ថាននេះទទួលបានការគាំទ្រពីក្រសួងអប់រំយុវជននិងកីឡាក្នុងកិច្ចសហប្រតិបត្តិការជាមួយគម្រោងព្រះរាជឧបត្ថម្ភរបស់ប្រទេសថៃសម្រាប់គាំទ្រដល់ប្រព័ន្ធអប់រំនៅកម្ពុជា។ ការិយាល័យហិរញ្ញវត្ថុមានការពាក់ព័ន្ធនៅក្នុងកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស ដែលមានចំណុចដូចខាងក្រោម៖

- លើកទឹកចិត្ត និងគាំទ្រដល់បុគ្គលិកសិក្សានិងនិស្សិតឱ្យបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្នុងផ្នែកបច្ចេកវិទ្យា ទាំងនៅក្នុងស្រុកនិងនៅក្រៅស្រុក ដើម្បីលើកកម្ពស់ជំនាញបង្រៀន និងប្រសិទ្ធភាពការងារ។
- ការបង្កើតផែនការអភិវឌ្ឍន៍រយៈពេលខ្លី និងរយៈពេលវែងសម្រាប់មន្ត្រីជំនួយ និងសាស្ត្រាចារ្យ។
- ព្យាយាមជំរុញកិច្ចសហការ ដើម្បីផ្តល់អាហារូបករណ៍ដល់បុគ្គលិករបស់វិទ្យាស្ថានក្នុងការបន្តការសិក្សារបស់ពួកគេនៅក្នុងស្ថាប័នអប់រំ ទាំងនៅក្នុងស្រុកនិងនៅក្រៅស្រុក។
- ការបង្កើតប្រព័ន្ធមួយដើម្បីវាយតម្លៃបុគ្គលិកបង្រៀនដោយគិតពិចារណាទៅលើសកម្មភាពសិក្សារបស់សិស្ស។

## ២.៣.២. យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល គឺជាគ្រឹះស្ថានឧត្តមសិក្សាមួយដែលមានទីតាំងនៅក្នុងស្រុកប្រាសាទសំបូរ ដែលជាតំបន់មិនសូវមានការអភិវឌ្ឍនៅក្នុងខេត្តកំពង់ធំ ដែលមានចម្ងាយជាង 200 គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ វិទ្យាស្ថាននេះដំណើរការសកម្មភាពបង្រៀន និងសកម្មភាពសិក្សានៅក្នុងកម្រិតទីបីក្នុង TVET ដោយផ្តោតសំខាន់លើបច្ចេកវិទ្យាឧស្សាហកម្ម និងកសិកម្ម។ វ.ប.ក.ឈ បាននិងកំពុងផ្តល់ថវិកាប្រចាំឆ្នាំជាច្រើនរបស់ខ្លួនដើម្បីធ្វើការអនុវត្តចំណុចកំណែទម្រង់ឧត្តមសិក្សាជាច្រើន ដូចជា៖

- ការចំណាយសម្រាប់ការកែលម្អគុណភាពនៃការបង្រៀន និងការរៀន និងការបង្កើតកម្មវិធីសិក្សានៅកម្រិតឧត្តមសិក្សា ជាពិសេសវគ្គសិក្សាតាមអនឡាញ។
- ចំណាយសម្រាប់ការលើកកម្ពស់ការស្រាវជ្រាវ និងការលើកទឹកចិត្តការប្រកួតប្រជែងការស្រាវជ្រាវ។
- គាំទ្រដល់ការបង្កើតគណៈកម្មការវាយតម្លៃគុណភាពផ្ទៃក្នុង។
- ការលើកកម្ពស់ការចុះឈ្មោះចូលរៀនរបស់សិស្សឧត្តមសិក្សា តាមរយៈការផ្តល់អាហារូបករណ៍ 100% និងអន្តេវាសិកដ្ឋានសម្រាប់និស្សិត និងសាស្ត្រាចារ្យ។

### ២.៣.៣. យុទ្ធសាស្ត្រគាំពារទ្រទ្រង់ការអភិវឌ្ឍយុវជន

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ក៏បានចែករំលែកថវិកាប្រចាំឆ្នាំរបស់ខ្លួនដើម្បីគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍យុវជន ដូចជា៖

- ការបង្កើតគម្រោងមួយចំនួនដើម្បីផ្តល់ឱកាសដល់ពលរដ្ឋវ័យក្មេង ដើម្បីទទួលបានការអប់រំប្រកបដោយគុណភាព ការបណ្តុះបណ្តាល មជ្ឈដ្ឋានសិក្សាល្អតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសរយៈពេលខ្លីនិងរយៈពេលវែង ដោយផ្តោតសំខាន់លើសកម្មភាព ការតាំងពិពណ៌ស្នាដៃនិស្សិត ទស្សនកិច្ចសិក្សា និងការហាត់ការ ។ល។
- ដំណើរការកម្មវិធីម្ចាស់អាជីវកម្មខ្នាតតូច ដើម្បីលើកទឹកចិត្តពលរដ្ឋវ័យក្មេងឱ្យមានគំនិតច្នៃប្រឌិត នវានុវត្តន៍ និងសហគ្រិនភាព តាមរយៈការបង្កើតផលិតផលដើម្បីលក់យកប្រាក់។
- គាំទ្រដល់បំណិតជីវិត និងកម្មវិធីថែទាំសុខភាព ដើម្បីបង្កើតភាពស័ក្តិសមខាងរូបរាងកាយ ចំណេះដឹង សីលធម៌របស់ពលរដ្ឋវ័យក្មេង ក៏ដូចជាបង្រៀនពួកគេពីរបៀបរស់នៅរួមគ្នាក្នុងសន្តិភាព និងសាមគ្គីភាព តាមរយៈការបញ្ជូននិស្សិតទៅចូលរួមក្នុងការវិស័យថ្នាក់ខេត្ត ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិដើម្បីចូលរួមជាមួយសិស្សពូកែទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ខេត្ត។

### ២.៣.៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍អប់រំកាយ និងកីឡា

វ.ប.ក.ឈ បានរួមចំណែកជាមួយប្រាក់ចំណូលរបស់ខ្លួនក្នុងការបង្កើតគម្រោងនានាពាក់ព័ន្ធនឹងអប់រំកាយនិងកីឡា ដោយបានផ្តោតជាសំខាន់លើ៖

### ២.៤. សក្តានុពលសម្រាប់ការរៀនសូត្រ ឬការផ្ទេរបន្ត

- វិស័យរដ្ឋនិងឯកជន ត្រូវបានអញ្ជើញឱ្យអភិវឌ្ឍនិងបង្កើតតំណភ្ជាប់ទីផ្សារការងារ ដើម្បីបំពេញតាមតម្រូវការនៃការរីកចម្រើនខាងវិស័យឧស្សាហកម្ម។
- ធ្វើការរួមបញ្ចូលគ្នារវាងទ្រឹស្តីជាមួយនឹងការអនុវត្តក្នុងមន្ទីរពិសោធន៍ រោងជាង និងកសិដ្ឋាន។
- ធ្វើការបង្កើតមូលនិធិវិទ្យាស្ថានដើម្បីធ្វើការរៃអង្គាសប្រាក់សម្រាប់ការអភិវឌ្ឍវិទ្យាស្ថាន។

### ២.៥. ព័ត៌មានបន្ថែមអំពីកិច្ចសហការ

វ.ប.ក.ឈ ក៏បានចុះ MoU ជាមួយគ្រឹះស្ថានជាច្រើន ទាំងក្នុងស្រុកនិងក្រៅស្រុកផងដែរ៖

- មជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេសនៃអង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ (SEAMEO TED) កម្ពុជា
- ក្រុមហ៊ុន Toshiba Co, Ltd. ប្រទេសថៃ
- សាកលវិទ្យាល័យ អាលីកាន់តេ ប្រទេសអេស្ប៉ាញ
- សាកលវិទ្យាល័យ មហាសារខាម ប្រទេសថៃ
- សាកលវិទ្យាល័យ រាជមង្គល រាជបាត មណ្ឌលឥសាន ប្រទេសថៃ
- សាកលវិទ្យា ដូឡាឡុងកន ប្រទេសថៃ

## ២.៦. ព័ត៌មានលម្អិតទំនាក់ទំនង

**វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល**

**<u>អាសយដ្ឋានបច្ចុប្បន្ន៖</u>** ភូមិសំបួរ ឃុំសំបួរ ស្រុកប្រាសាទសំបួរ ខេត្តកំពង់ធំ ព្រះរាជាណាចក្រកម្ពុជា

**អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុនៃគម្រោង BALANCE**

1- **បណ្ឌិត ប៉ិច ស៊ាង**
តួនាទី៖ អ្នកគ្រប់គ្រង
ទូរសព្ទ៖ (+855) 89 365 861
អ៊ីម៉ែល៖ pechseangchula@gmail.com គេហទំព័រ
http://www.kcit.edu.kh

2- **លោក សុខឃឿន**
តួនាទី៖ អ្នកស្រាវជ្រាវ ទូរសព្ទ៖
(+855) 12 456 436
អ៊ីម៉ែល៖
គេហទំព័រ៖ http://www.kcit.edu.kh

3- **លោក ជុំ សុជាតិ**
តួនាទី៖ មន្ត្រីបច្ចេកទេស ទូរសព្ទ៖
(+855) 11 444 004
អ៊ីម៉ែល៖ chumsocheatmymail@gmail.com
គេហទំព័រ៖ http://www.kcit.edu.kh

4- **លោក ស៊ុំ សាន់**
តួនាទី៖ មន្ត្រីបច្ចេកទេសនិងរដ្ឋបាល
ទូរសព្ទ៖ (+855) 95 265 400
អ៊ីម៉ែល៖ sumsun.buu@gmail.com
គេហទំព័រ៖ http://www.kcit.edu.kh

# វិទ្យាស្ថានបច្ចេកវិទ្យា កំពង់ស្ពឺ

## ( វ.ប.ក.ស )

# ៣
# វិទ្យាស្ថានបច្ចេកវិទ្យា កំពង់ស្ពឺ (វ.ប.ក.ស)

## លើកកម្ពស់គុណភាពការអប់រំរបស់និស្សិតតាមរយៈការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់សាស្ត្រាចារ្យ

### ៣.១. សាវតារ

វិទ្យាស្ថានបច្ចេកវិទ្យា កំពង់ស្ពឺ (វ.ប.ក.ស) គឺជាគ្រឹះស្ថានឧត្តមសិក្សាមួយ ដែលផ្ដោតសំខាន់លើបច្ចេកវិទ្យាកសិកម្មនិងឧស្សាហកម្ម ដែលគ្របដណ្ដប់លើផ្ទៃដី 200 ហិចតា និងមានទីតាំងនៅភូមិអូរអង្គំ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ព្រះរាជាណាចក្រកម្ពុជា។ វិទ្យាស្ថាននេះត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ 32 អនក្រ.បក ចុះថ្ងៃទី20 ខែឧសភា ឆ្នាំ 2015 ដោយរាជរដ្ឋាភិបាលកម្ពុជា។

បច្ចុប្បន្ននេះ វ.ប.ក.ស ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា នៃប្រទេសកម្ពុជា។ វិទ្យាស្ថាននេះទទួលបានការឧបត្ថម្ភពីព្រះអង្គម្ចាស់ក្សត្រិយ៍មហាចក្រីសិរិនថន នៃប្រទេសថៃ តាមរយៈគម្រោងអប់រំនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចសហប្រតិបត្តិការស៊ីជម្រៅជាមួយគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេសថៃ។

វ.ប.ក.ស បានបង្កើតផែនការយុទ្ធសាស្ត្រឆ្នាំ 2017-2022 ដែលជាផែនទីបង្ហាញផ្លូវមួយសម្រាប់កិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចចក្ខុវិស័យ៖ ដើម្បីក្លាយខ្លួនទៅជាគ្រឹះស្ថានឧត្តមសិក្សារដ្ឋដែលឈានមុខគេថ្នាក់ខេត្ត ដែលមានភាពលេចធ្លោក្នុងបច្ចេកវិទ្យាកសិកម្ម និងឧស្សាហកម្ម គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដោយប្ដេជ្ញាចិត្តដើម្បីបម្រើដល់ការអភិវឌ្ឍប្រកបដោយចីរភាពថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ។ បេសកកម្មរបស់ វ.ប.ក.ស គឺដើម្បីផ្ដល់ឱកាសដល់និស្សិតដែលរស់នៅក្នុងតំបន់ដាច់ស្រយាល ដែលគ្មានលទ្ធភាពបង់ថ្លៃសិក្សានៅតាមបណ្ដាទីក្រុងធំៗ និងដើម្បីទទួលបានការអប់រំបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព។

បច្ចុប្បន្ននេះ មានសិស្សអាហារូបករណ៍ 100% ចំនួន 230 នាក់ ដែលបានចុះឈ្មោះចូលរៀនក្នុងមុខវិជ្ជាឯកទេសចំនួនប្រាំមួយ រួមមាន វិទ្យាសាស្ត្រដំណាំ វិទ្យាសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល កុំព្យូទ័រធុរកិច្ច ការដំឡើងប្រព័ន្ធអគ្គិសនី និងបច្ចេកវិទ្យាអាហារ។ ដំណើរការនៃការជ្រើសរើសអាហារូបករណ៍ មានដូចខាងក្រោម៖

- ក្រសួងអប់រំ យុវជន និងកីឡា បានបោះពុម្ពផ្សាយសៀវភៅណែនាំស្តីពីអាហារូបករណ៍ រួចចែកចាយទៅតាមវិទ្យាល័យ នៅទូទាំងប្រទេស ដើម្បីប្រមូលយកទម្រង់ពាក្យស្នើសុំអាហារូបករណ៍ដែលបានបំពេញរួច។ បន្ទាប់មក ក្រសួងអប់រំ យុវជន និងកីឡាធ្វើការវាយតម្លៃពាក្យស្នើសុំរបស់អ្នកដាក់ពាក្យស្នើសុំ រួចជ្រើសរើសបេក្ខជនជាប់អាហារូបករណ៍ដោយជោគជ័យ (សម្រាប់តែថ្នាក់បរិញ្ញាបត្រតែប៉ុណ្ណោះ) រួចផ្ញើលទ្ធផលទៅកាន់ វ.ប.ក.ស។
- វ.ប.ក.ស រៀបចំការប្រឡងអារូបករណ៍ដើម្បីជ្រើសរើសនិស្សិតទាំងថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រ។ ដំណើរការនេះ ត្រូវបានជូនដំណឹងដល់សាធារណជនប្រហែលជាមួយខែមុន។ បន្ទាប់មក វ.ប.ក.ស ប្រគល់លទ្ធផលអាហារូបករណ៍ទៅកាន់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីទទួលស្គាល់ជាផ្លូវការ។ នៅពេលដែលក្រសួងអប់រំ យុវជន និងកីឡា ទទួលបានបញ្ជីបេក្ខជនជាប់ស្ពាពរពី វ.ប.ក.ស ហើយ លទ្ធផលផ្លូវការដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ត្រូវចេញផ្សាយជាសាធារណៈ និងផ្ញើទៅកាន់ វ.ប.ក.ស។ ដោយមានការបង្កើតគណៈកម្មការជ្រើសរើសផ្ទៃក្នុង បន្ទាប់មក វ.ប.ក.ស នឹងបើកកិច្ចប្រជុំដើម្បីពិភាក្សាវាយតម្លៃ និងជ្រើសរើសនិស្សិតអាទិភាព ដើម្បីទទួលបានប្រាក់ឧត្ថម្ភប្រចាំខែ ដើម្បីគាំទ្រដល់ការរស់នៅនិងសិក្សាប្រចាំថ្ងៃរបស់ពួកគេ។ និស្សិតអាទិភាព សំដៅលើនិស្សិតក្រីក្រ និង/ឬនិស្សិតជួបការលំបាក ដោយមានលិខិតបញ្ជាក់ពីអាជ្ញាធរ។ វ.ប.ក.ស ជ្រើសរើសនិស្សិតថ្នាក់បរិញ្ញាបត្ររងចំនួន 30% និងនិស្សិតថ្នាក់បរិញ្ញាបត្រចំនួន 10% ផ្អែកលើអនុក្រឹត្យលេខ 174 អនក្រ.បក ចុះថ្ងៃទី04 ខែឧសភា ឆ្នាំ2014 ស្តីពីអារូបករណ៍ និងជំនួយអន្តេវាសិកដ្ឋានសម្រាប់សិស្សក្នុងគ្រឹះស្ថានរដ្ឋ។ វ.ប.ក.ស ដាក់លិខិតស្នើសុំទៅកាន់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលបានប្រាក់ឧត្ថម្ភអារូបករណ៍។

វ.ប.ក.ស មានបទពិសោធន៍ក្នុងការធ្វើកិច្ចសហប្រតិបត្តិការក្នុងការសិក្សាស្រាវជ្រាវជាមួយអង្គការជាច្រើន ឧទាហរណ៍ ក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សានៅក្នុងប្រទេសថៃ នៅក្នុងវិស័យអភិវឌ្ឍន៍កសិកម្ម អភិវឌ្ឍន៍ឧស្សាហកម្ម កំណែទម្រង់ការអប់រំ ការវាយតម្លៃការអប់រំ យុទ្ធសាស្រ្តការអប់រំ និងការអប់រំវិជ្ជាជីវៈ។

*ប្រភេទនៃឧត្តមានុវត្តន៍៖ ឥទ្ធិពលនៃការគ្រប់គ្រងហិរញ្ញវត្ថុលើការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់សាស្ត្រាចារ្យ និងគុណភាពនិស្សិត។*

## ៣.២. ព័ត៌មានលម្អិតអំពីឧត្តមានុវត្តន៍

ក្នុងអំឡុងឆ្នាំមុននេះ វ.ប.ក.ស បានសម្រេចជោគជ័យក្នុងការបង្កើតនិស្សិតដែលមានគុណវុឌ្ឍិ ក្នុងការបម្រើការក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម ក៏ដូចជាបម្រើដល់សង្គមជាតិផងដែរ។ ដោយសារតែការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ព្រមទាំងការផ្តល់ឱកាសសម្រាប់ប្រតិបត្តិការមានលក្ខណៈសមរម្យ បុគ្គលិកភាគច្រើនមានការអភិវឌ្ឍខ្លួន ហើយ

និស្សិតដែលបានបញ្ចប់ការសិក្សាពីកម្មវិធីសិក្សានេះ អាចបង្កើតអាជីវកម្មផ្ទាល់ខ្លួនបាន ធ្វើការក្នុងសហគ្រាសឯកជន និងបន្តការសិក្សារបស់ពួកគេនៅកម្រិតខ្ពស់។ សមិទ្ធផលដែលសម្រេចបាន កើតចេញពីសកម្មភាពផែនការថវិកាជាច្រើន ដូចជា៖

### ក. ការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់សាស្ត្រាចារ្យ

- កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជនក្នុងការរៀបចំការបណ្តុះបណ្តាលរយៈពេលខ្លី ដំណើរកម្សាន្តទៅកាន់មូលដ្ឋាន ការផ្ទេរបច្ចេកវិទ្យាបច្ចុប្បន្ន ការធ្វើការសិក្សាស្រាវជ្រាវរួមគ្នាស្តីពីនវានុវត្តន៍ និងការអភិវឌ្ឍនិងការត្រួតពិនិត្យកម្មវិធីសិក្សាឡើងវិញ ដើម្បីបំពេញតាមតម្រូវការទីផ្សារ។
- ការរៀបចំការអភិវឌ្ឍសមត្ថភាពផ្ទៃក្នុងតាមរយៈការផ្តល់ការបង្រៀនណែនាំដល់សាស្ត្រចារ្យដែលមានបទពិសោធន៍ថ្មី ដើម្បីឱ្យពួកគេអាចមានទំនុកចិត្តច្រើនជាងមុន ដើម្បីបំពេញកិច្ចការរបស់ពួកគេ ដោយបង្កើតគណៈកម្មការសិក្សាជំនាញវិជ្ជាជីវៈផ្ទៃក្នុង (PLC)។ សមាគមសាស្ត្រាចារ្យត្រូវបានបង្កើតឡើងដើម្បីចែករំលែកនិងផ្លាស់ប្តូរគំនិតពាក់ព័ន្ធនឹងការបង្រៀន ក៏ដូចជាដើម្បីផ្តល់ជាដំណោះស្រាយចំពោះបញ្ហាប្រឈមនាពេលបច្ចុប្បន្នក្នុងការបង្រៀន។ ដំណើរការនៃ PLC អាចត្រូវអនុវត្តទល់មុខផ្ទាល់ ឬតាមរយៈការសន្ទនាគ្នាតាមអនឡាញ។ ក្នុងករណីនៃកិច្ចប្រជុំទល់មុខផ្ទាល់ ត្រូវកំណត់ពេលវេលាសម្រាប់ការប្រជុំប្រចាំខែ។ បន្ថែមលើនេះ ការអភិវឌ្ឍសមត្ថភាព ត្រូវបានធ្វើឡើងតាមរយៈការផ្សព្វផ្សាយ និងការលើកទឹកបុគ្គលិកបង្រៀនឱ្យធ្វើការស្រាវជ្រាវលើនវានុវត្តន៍ និងការលើកទឹកចិត្តឱ្យបន្តការសិក្សារយៈពេលវែង។
- ការបង្កើតការតាំងចិត្តខ្លួនឯងដើម្បីការសិក្សាពេញមួយជីវិត ដោយមានចិត្តក្លៀវក្លាចង់រៀនសូត្រ និងស្វែងយល់បន្ថែមទៀតអំពីការអភិវឌ្ឍន៍ពិភពលោកនាពេលបច្ចុប្បន្ន ជាពិសេសចំណេះដឹង និងជំនាញក្នុងផ្នែកបង្រៀនរបស់ពួកគេ។ មានការចង់ចេះចង់ដឹងក្នុងការអភិវឌ្ឍខ្លួន កំណត់ពីផ្នែកត្រូវកែលម្អដោយខ្លួនឯង តាមរយៈការវាយតម្លៃលើខ្លួនឯង និងយោបល់ត្រឡប់ដោយប្រមូលបានពីការវាយតម្លៃរបស់និស្សិត និងការធ្វើការវាយតម្លៃខ្លួនឯងជាប្រចាំ ដោយប្រើគំរូផែនការ អនុវត្ត ត្រួតពិនិត្យ និងចាត់វិធានការ (PLAN-DO-CHECK-ACTION, PDCA)។

### ខ. ការលើកកម្ពស់គុណភាពក្នុងការអប់រំនិស្សិត

- អនុវត្តកម្មវិធីអាហារូបករណ៍៖ និស្សិតត្រូវបានផ្តល់ជូននូវការសិក្សាដោយឥតគិតថ្លៃ និងអន្តេវាសិកដ្ឋាន។
- អនុវត្តគម្រោងផែនការសិក្សាលក្ខណៈបុគ្គល (ISP)៖ និស្សិតទទួលបានឱកាសក្នុងការធ្វើដំណើរទស្សនកិច្ចនៅនឹងកន្លែងផ្ទាល់ ទៅកាន់សហគ្រាសមួយចំនួន ក្នុងអំឡុងពេលនៃការសិក្សារបស់ពួកគេក្នុងឆមាសទីមួយ ដើម្បីបណ្តុះស្មារតីរៀនសូត្រក្លៀវក្លារបស់ពួកគេ។ ជា

លទ្ធផល និស្សិតនឹងកំណត់ពីចំណាប់អារម្មណ៍ក្នុងការរៀនសូត្ររបស់ពួកគេលើឱកាសទៅអនាគតក្រោយពីបានទស្សនកិច្ចនៅសហគ្រាសរួច។

- បើកដំណើរការកម្មវិធីប្រឹក្សាយោបល់សម្រាប់មាគ៌ាសិក្សារបស់និស្សិត៖ និស្សិតម្នាក់ៗត្រូវបានកំណត់ឱ្យមានអ្នកប្រឹក្សាយោបល់ផ្ទាល់របស់ពួកគេ។ និស្សិតអាចទាមទារការប្រឹក្សាយោបល់ពាក់ព័ន្ធនឹងបញ្ហាការសិក្សាទាំងអស់ ជាមួយអ្នកប្រឹក្សាយោបល់របស់ពួកគេ ដើម្បីសម្រេចនូវគោលដៅនៃការសិក្សារបស់ពួកគេ។
- ផ្តល់ការគាំទ្រដល់និស្សិត៖ និស្សិតអាចទទួលបានការប្រើប្រាស់អ៊ីនធឺណិតដោយឥតគិតថ្លៃនៅក្នុងបរិវេណវិទ្យាស្ថាន និងអាចអនុវត្តការសិក្សាពីចម្ងាយរបស់ពួកគេបានតាមរយៈប្រព័ន្ធគ្រប់គ្រងការរៀនសូត្រ (LMS)។
- គាំទ្រដល់ការរុករកនវានុវត្តន៍ និងគម្រោងចូលរួមដោយផ្ទាល់៖ និស្សិតសប្បាយចិត្តនៅពេលដែលពួកគេទទួលបានឱកាសក្នុងការស្វែងយល់ពីអ្វីៗដែលថ្មី ដោយប្រើមន្ទីរពិសោធន៍ និងកន្លែងផលិត ដើម្បីដំណើរការគម្រោងរបស់ពួកគេ។ ឧទាហរណ៍ និស្សិតធ្វើការពិសោធន៍លើការបង្កាត់ពូជសត្វ ដោយព្យាយាមប្រើរូបមន្តខុសៗគ្នានៃចំណីសត្វ និងការបង្កើតថាមពលពន្លឺព្រះអាទិត្យ។
- ផ្សារភ្ជាប់កម្មវិធីសិក្សាជាមួយនឹងតម្រូវការឧស្សាហកម្ម។ អាកប្បកិរិយាសិក្សាវិជ្ជមាន គឺជាកត្តាគន្លឹះនៅក្នុងការជោគជ័យរបស់និស្សិត ពាក់ព័ន្ធនឹងសកម្មភាពសិក្សា។ ដើម្បីមានអាកប្បកិរិយាបែបនេះ គប្បីត្រូវគិតគូរឱ្យបានហ្មត់ចត់ពីធាតុចូល ឧទាហរណ៍ ការផ្តល់ជូនកម្មវិធីសិក្សាដែលឆ្លើយតបនឹងតម្រូវការសិស្ស ការរួមបញ្ចូលបច្ចេកវិទ្យាជាមួយនឹងការបង្កើត ការកសាងមជ្ឈដ្ឋានសិក្សាវិជ្ជមានដោយផ្តល់កិច្ចការគម្រោងដែលត្រូវប្រគល់ជូនមិនសូវស្មុគស្មាញ និងការចាត់តាំងបុគ្គលិកបង្រៀនដែលមានសមត្ថភាព ដើម្បីអនុវត្តកិច្ចការបង្រៀន។

## ៣.៣. ឥស្សរភាពនៃភាពជោគជ័យ (លទ្ធផលដែលសម្រេចបាន)

ផ្អែកលើផែនការប្រតិបត្តិការប្រចាំឆ្នាំសម្រាប់ឆ្នាំ2020 វិទ្យាស្ថាននេះបានចាប់ផ្តើម និងបញ្ចប់ការអនុវត្តរាល់សកម្មភាពទាំងអស់ (100%)។ លទ្ធផលនៃការអនុវត្តសកម្មភាពមានដូចខាងក្រោម៖

- 80% នៃសាស្ត្រាចារ្យនិងបុគ្គលិក ទទួលបានការអភិវឌ្ឍជំនាញវិជ្ជាជីវៈបន្ថែម។ ចំនួននេះធ្វើឱ្យមានការកើនឡើង 10% បើធៀបនឹងឆ្នាំចាស់។
- 94% នៃនិស្សិតដែលបញ្ចប់ការសិក្សាពីកម្មវិធីនេះ បង្កើតអាជីវកម្មផ្ទាល់ខ្លួន ធ្វើការនៅក្នុងសហគ្រាសឯកជន ឬបន្តការសិក្សានៅកម្រិតខ្ពស់។
- 70% នៃសាស្ត្រាចារ្យនិងបុគ្គលិក ត្រូវបានចាត់តាំងឱ្យបំពេញកិច្ចការស្របតាមលក្ខណៈសម្បត្តិរបស់ពួកគេ។ ចំនួននេះធ្វើឱ្យមានការកើនឡើង 10% បើធៀបនឹងឆ្នាំចាស់។

បន្ថែមលើនេះ ប្រព័ន្ធ IT ត្រូវបានបង្កើតឡើង និងដាក់ដំណើរការ ដើម្បីជួយដល់ប្រតិបត្តិការរបស់ស្ថាប័ន។

## ៣.៤. សក្ដានុពលសម្រាប់ការរៀនសូត្រ ឬការផ្ទេរបន្ត

- វិស័យរដ្ឋ និងវិស័យឯកជន ត្រូវបានអញ្ជើញឱ្យជួយដល់ការអភិវឌ្ឍដើម្បីបំពេញតាមតម្រូវការខាងឧស្សាហកម្មសម្រាប់ការរីកចម្រើន។
- ផ្សារភ្ជាប់ទ្រឹស្តីជាមួយនឹងការអនុវត្ត។

## ៣.៥. ព័ត៌មានបន្ថែម

- វិទ្យាស្ថានបច្ចេកវិទ្យា កំពង់ស្ពឺ បានទទួលជំនួយឧបត្ថម្ភពីព្រះរាជនូបត្ថម្ភរបស់ព្រះអង្គម្ចាស់ក្សត្រិយ៍មហាចក្រីសិរិនថននៃប្រទេសថៃ។
- វ.ប.ក.ស ក៏បានចុះ MoU ជាមួយគ្រឹះស្ថានជាច្រើន ទាំងក្នុងស្រុកនិងក្រៅស្រុកផងដែរ
  - មជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេសនៃអង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ (SEAMEO TED) កម្ពុជា
  - វិទ្យាស្ថានអប់រំវិជ្ជាជីវៈកសិកម្ម តំបន់ភាគកណ្តាល 1, 2 និង 3, ប្រទេសថៃ ដោយមានកិច្ចសហប្រតិបត្តិការជាមួយវិស័យអប់រំ។
  - ក្រុមហ៊ុន Toshiba Co, Ltd. ប្រទេសថៃ
  - មហាវិទ្យាល័យបច្ចេកទេស វិជ្ជាជីវៈ ទៀនជិន ប្រទេសចិន
  - សាកលវិទ្យាល័យ អាលីកាន់តេ ប្រទេសអេស្ប៉ាញ

## ៣.៦. ព័ត៌មានលម្អិតទំនាក់ទំនង

**វិទ្យាស្ថានបច្ចេកវិទ្យា កំពង់ស្ពឺ**

**អាសយដ្ឋានបច្ចុប្បន្ន៖** ភូមិអូរអង្គំ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ព្រះរាជាណាចក្រកម្ពុជា។

**អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុនៃគម្រោង BALANCE**

**1- បណ្ឌិត ហុង គឹមឈាង**

តួនាទី៖ អ្នកគ្រប់គ្រង

ទូរសព្ទ៖ (+855) 12 225 303

អ៊ីម៉ែល៖ kimcheang@ksit.edu.kh

គេហទំព័រ៖ http://www.ksit.edu.kh

**2- បណ្ឌិត ហាត ប៊ុនហេ** តួនាទី៖

អ្នកស្រាវជ្រាវ ទូរសព្ទ៖ (+855) 85

483 609

អ៊ីម៉ែល៖ bunhe@ksit.edu.kh គេហទំព័រ៖

http://www.ksit.edu.kh

**3- លោក ហុង ចាន់លី**

តួនាទី៖ មន្ត្រីបច្ចេកទេស ទូរសព្ទ៖

(+855) 11 425 279

អ៊ីម៉ែល៖ channly@ksit.edu.kh

គេហទំព័រ http://www.ksit.edu.kh

**4- លោក សាន់ សាវុទ្ធ**

តួនាទី៖ មន្ត្រីបច្ចេកទេសនិងរដ្ឋបាល ទូរសព្ទ៖

(+855) 17/10 45 45 95

អ៊ីម៉ែល៖ savuthsann@ksit.edu.kh គេហទំព័រ http://www.ksit.edu.kh

# វិទ្យាស្ថានជាតិអប់រំ

# ៤
# វិទ្យាស្ថានជាតិអប់រំ

## ប្រាក់រង្វាន់លើកទឹកចិត្តផ្អែកតាមសកម្មភាពការងារសម្រាប់ការបង្កើនផលិតភាព និងការកសាងមុខមាត់របស់សាកលវិទ្យាល័យ៖ ករណីវិទ្យាស្ថានជាតិអប់រំ (វជអ)

### ៤.១. សាវតារ

វិទ្យាស្ថានជាតិអប់រំ (វជអ) ដែលបច្ចុប្បន្ននេះ មានទីតាំងនៅចំបេះដូងនៃរាជធានីភ្នំពេញ ហើយត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ1941 គឺជាគ្រឹះស្ថានឧត្តមសិក្សាចាស់ជាងគេបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ វិទ្យាស្ថាននេះជាគ្រឹះស្ថានរដ្ឋមួយ ដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ពីក្រសួងអប់រំ យុវជន និងកីឡា (ក្រ អយក)។ ចាប់ពីពេលនោះមក វិទ្យាស្ថាននេះត្រូវអភិវឌ្ឍនិងផ្លាស់ប្តូរឈ្មោះតាមវេលាប្រវត្តិសាស្ត្រ៖
(1) ក្នុងឆ្នាំ1941 ជាសាលាគរុកោសល្យ (2) ក្នុងឆ្នាំ1958 ជាវិទ្យាស្ថានជាតិ គរុកោសល្យ (3) ក្នុងឆ្នាំ1965 ជាមហាវិទ្យាល័យគរុកោសល្យ (4) ក្នុងឆ្នាំ 1975-1979 មហាវិទ្យាល័យគរុកោសល្យត្រូវបានបិទ និងបំផ្លាញដោយពួកខ្មែរក្រហម។ របបនេះមានឈ្មោះថា វាលពិឃាត (5) សាលានយោបាយសម្រាប់ ក្រ អយក ក្នុងឆ្នាំ1979។ (6) ក្នុងឆ្នាំ1980 ជាសាលាបណ្តុះបណ្តាលគ្រូកម្រិតមធ្យម និងគរុកោសល្យ (7) ក្នុងឆ្នាំ1986 ជាសាកលជាន់ខ្ពស់សម្រាប់មន្ត្រីរដ្ឋបាលអប់រំ (8) ក្នុងឆ្នាំ1992 ជាមហាវិទ្យាល័យគរុកោសល្យ (9) ក្នុងឆ្នាំ2004 ជាវិទ្យាស្ថានជាតិអប់រំ ដែលជាឈ្មោះពិតប្រាកដរបស់វិទ្យាស្ថាននេះ។

យោងតាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា និងកំណែទម្រង់ផ្អែកលើសរសរស្តម្ភទាំង 5 សម្រាប់ការលើកកម្ពស់គុណភាពធនធានមនុស្ស វិទ្យាជាតិអប់រំ ដែលជាគ្រឹះស្ថានតែមួយគត់ក្នុងការផ្តល់នូវការផ្លាស់ប្តូរការបណ្តុះបណ្តាលគ្រូកម្រិតឧត្តម និងការគ្រប់គ្រងអប់រំជាផ្លូវការ នៅគ្រប់កម្រិតនៅក្នុងប្រទេស បានអនុវត្តផែនការយុទ្ធសាស្ត្រមួយ ក៏ដូចតួនាទីនិងទំនួលខុសត្រូវ ជាពិសេសផ្តោតសំខាន់លើការបណ្តុះបណ្តាលគ្រូបង្រៀន រួមទាំងការបណ្តុះបណ្តាលដំបូង (Pre-service) និងការបណ្តុះបណ្តាលបន្ត (In-service) ផងដែរ។

Co-funded by the Erasmus+ Programme of the European Union

ទីមួយ សម្រាប់ការបណ្តុះបណ្តាលដំបូង (Pre-service) វិទ្យាស្ថានជាតិអប់រំបានផ្តល់ការបណ្តុះបណ្តាលសម្រាប់ (1) គ្រូបង្រៀនកម្រិតឧត្តមគ្រប់មុខវិជ្ជាឯកទេស (2) គ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសភាសាបារាំង-ខ្មែរ (3) បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ (4) អធិការអប់រំតាមប្រព័ន្ធអធិការកិច្ចថ្មី (5) ការបណ្តុះបណ្តាលនាយកសាលា និង (6) បណ្ឌិតផ្នែកគ្រប់គ្រងអប់រំ។

ទីពីរ ចំពោះការបណ្តុះបណ្តាលបន្ត (In-service) វិទ្យាស្ថានជាតិអប់រំបាន (1) ធ្វើការបណ្តុះបណ្តាលជាបន្តបន្ទាប់ដល់អធិការអប់រំមានស្រាប់ ស្តីពីប្រព័ន្ធអធិការកិច្ចថ្មី (2) បំប៉នសមត្ថភាពគ្រូវិទ្យាល័យលើខ្លឹមសារវិធីសាស្ត្រ និងជំនាញពិសោធន៍វិទ្យាសាស្ត្រ (3) បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងអប់រំថ្នាក់រាជធានី/ខេត្ត លើការរៀបចំផែនការវិស័យអប់រំនៅកម្ពុជា (4) បណ្តុះបណ្តាលនាយក/នាយិកាវិទ្យាល័យស្តីពីប្រព័ន្ធអធិការកិច្ចថ្មី និង (5) បណ្តុះបណ្តាលនាយក/នាយិកា និងនាយករង/នាយិការងនៃសាលាមធ្យមសិក្សាធនធាន ដែលទទួលខុសត្រូវលើសាលារៀន និងមន្ទីរពិសោធន៍ក្នុង 25 ខេត្ត/រាជធានី។

គោលដៅរបស់វិទ្យាស្ថានជាតិអប់រំ (វជអ) គឺដើម្បីធ្វើការផ្លាស់ប្តូរ វជអ ឱ្យក្លាយជាគ្រឹះស្ថានឧត្តមសិក្សាដែលទទួលបន្ទុកលើការបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា និងបុគ្គលិកគ្រប់គ្រងការអប់រំ។ វជអ មានគោលដៅចំនួនបួន៖ (1) ការបណ្តុះបណ្តាលនិងការអភិវឌ្ឍគ្រូបង្រៀនដែលមានគុណភាព និងឆ្លើយតបតាមតម្រូវការនៅក្នុងប្រទេសនិងតំបន់ (2) គុណភាពក្នុងការបណ្តុះបណ្តាលមន្ត្រីអប់រំ និងការអភិវឌ្ឍនៅក្នុងប្រទេស និងតំបន់ (3) សមត្ថភាពស្រាវជ្រាវរបស់មន្ត្រីអប់រំ គរុនិស្សិតក្នុងការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្តក្នុងផ្នែកគរុកោសល្យ និងវិធីសាស្ត្របង្រៀនថ្មី និង (4) ភាពជាអ្នកដឹកនាំល្អប្រសើរ ការគ្រប់គ្រងធនធានមនុស្ស និងការប្តេជ្ញាចិត្តចំពោះបរិស្ថាន។

***ប្រភេទនៃឧត្តមានុវត្តន៍៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ប្រាក់រង្វាន់លើកទឹកចិត្ត និងផលិតភាព។***

## ៤.២. ព័ត៌មានលម្អិតអំពីឧត្តមានុវត្តន៍

ផ្អែកទៅលើផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា និងកំណែទម្រង់ផ្អែកលើសរសរស្តម្ភទាំង 5 សម្រាប់ការលើកកម្ពស់គុណភាពធនធានមនុស្ស វិទ្យាជាតិអប់រំ ដែលជាគ្រឹះស្ថានតែមួយគត់ក្នុងការផ្តល់នូវការផ្លាស់ប្តូរការបណ្តុះបណ្តាលគ្រូកម្រិតឧត្តម និងការគ្រប់គ្រងអប់រំជាផ្លូវការ នៅគ្រប់កម្រិតនៅក្នុងប្រទេស បានអនុវត្តផែនការយុទ្ធសាស្ត្រមួយ ក៏ដូចជាតួនាទីនិងទំនួលខុសត្រូវជាពិសេសផ្តោតសំខាន់លើការបណ្តុះបណ្តាលគ្រូបង្រៀនរួមទាំងការបណ្តុះបណ្តាលដំបូង (Pre-service) និងការបណ្តុះបណ្តាលបន្ត (In-service) ផងដែរ។ ចំពោះការបណ្តុះបណ្តាលដំបូង វិទ្យាស្ថានជាតិអប់រំបានផ្តល់ការបណ្តុះបណ្តាលសម្រាប់ (1) គ្រូបង្រៀនកម្រិតឧត្តមគ្រប់មុខវិជ្ជាឯកទេស (2) គ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសភាសាបារាំង និងគណិតវិទ្យា ភាសាបារាំងនិងជីវវិទ្យា និងភាសាបារាំងនិងរូបវិទ្យា (3) បរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំ បរិញ្ញាបត្រជាន់ខ្ពស់វិធីសាស្ត្របង្រៀនជាភាសាបារាំងនិងបរិញ្ញាបត្រជាន់ខ្ពស់អប់រំក្នុងផ្នែកប្រឹក្សាយោបល់គរុកោសល្យ (4) បណ្ឌិតផ្នែកគ្រប់គ្រងអប់រំ (5) អធិការអប់រំតាមប្រព័ន្ធអធិការកិច្ចថ្មី (អធិការកិច្ចជាប្រព័ន្ធ) និង (6) ការបណ្តុះបណ្តាលនាយកសាលា។

វជអ មានស្វ័យភាពក្នុងការដំណើរការការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន។ អ្នកដើរតួនាទីសំខាន់ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រងហិរញ្ញវត្ថុរបស់ វជអ គឺជាប្រធានក្រុមប្រឹក្សាភិបាល នាយក នាយករងដែលទទួលបន្ទុកការិយាល័យគណនេយ្យ ប្រធានដេប៉ាតឺម៉ង់ ប្រធានការិយាល័យ និងប្រធានការិយាល័យគណនេយ្យ។ វជអ មានសិទ្ធិអំណាចពេញលេញក្នុងការបង្គាប់ដល់ការគ្រប់គ្រងហិរញ្ញវត្ថុដើម្បីបង្កើនថវិកាសម្រាប់ការអនុវត្តសកម្មភាព។ ដេប៉ាតឺម៉ង់ និងការិយាល័យនីមួយៗ អាចស្នើសកម្មភាព និងថវិកានៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ (AOP) បាន។

ម្យ៉ាងវិញទៀត មានគម្រោងមួយចំនួន ដែលគាំទ្រដោយ វជអ ក្នុងការអភិវឌ្ឍសមត្ថភាព ការកែលម្អ ការធ្វើទំនើបកម្ម និងការអភិវឌ្ឍបរិវេណនៅ វជអ ឡើងវិញក្នុងពេលនោះ ក៏ផ្តល់ជូននូវសម្ភារៈសម្រាប់ការកែលម្អនោះ ក៏ដូចជាសម្រាប់ការបង្រៀន និងការរៀនផងដែរ។ វជអ មានសិទ្ធិក្នុងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឡើងវិញ ផ្អែកតាមស្វ័យភាពដែលរដ្ឋាភិបាលបានប្រគល់ជូន។ វិទ្យាស្ថាននេះក៏មានសិទ្ធិក្នុងការបង្កើនប្រាក់ចំណូលដែលបានពីសកម្មភាពតាមរយៈទ្រព្យសម្បត្តិរបស់ វជអ ដើម្បីបង្កើនប្រាក់ចំណូលរបស់ប្រចាំថ្នាំរបស់ខ្លួន។ ទាំងនេះរួមបញ្ចូលទាំងការស្រាវជ្រាវ និងការប្រឹក្សាយោបល់ ដែលអនុវត្តសម្រាប់ឧស្សាហកម្ម ការបរិច្ចាគ និងការឧបត្ថម្ភ និងប្រាក់ចំណូលដែលរកបានពីសកម្មភាពធុរកិច្ចផងដែរ។

បន្ថែមលើនេះ ចំពោះការបណ្តុះបណ្តាលបន្ត វិទ្យាស្ថានជាតិអប់រំបាននិងកំពុង (1) ធ្វើការបណ្តុះបណ្តាលជាបន្តបន្ទាប់ដល់អធិការអប់រំមានស្រាប់ ស្តីពីប្រព័ន្ធអធិការកិច្ចថ្មី (2) បំប៉នសមត្ថភាពគ្រូវិទ្យាល័យលើខ្លឹមសារ និងវិធីសាស្ត្របង្រៀន និងជំនាញពិសោធន៍វិទ្យាសាស្ត្រ (3) បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងអប់រំថ្នាក់រាជធានី/ខេត្ត លើការរៀបចំផែនការវិស័យអប់រំនៅកម្ពុជា (4) បណ្តុះបណ្តាលនាយក/នាយិកាវិទ្យាល័យស្តីពីប្រព័ន្ធអធិការកិច្ចថ្មី។ ម្យ៉ាងវិញទៀត វជអ កំពុងធ្វើការត្រួតពិនិត្យឡើងវិញលើផែនការយុទ្ធសាស្ត្ររបស់ខ្លួន ក៏ដូចជាការកែលម្អបរិវេណវិទ្យាស្ថាន និងហេដ្ឋារចនាសម្ព័ន្ធទាំងមូលផងដែរ។ សាស្ត្រាចារ្យកំពុងធ្វើការពង្រឹងសមត្ថភាពនៃការអប់រំនិងជំនាញ តាមរយៈវិធានការដូចជា (1) ត្រួតពិនិត្យកម្មវិធីសិក្សាបច្ចុប្បន្នឡើងវិញដើម្បីបំពេញតាមតម្រូវការទីផ្សារការងារ (2) លើកកម្ពស់គរុកោសល្យ និងវិធីសាស្ត្របង្រៀនតាមរយៈសិក្ខាសាលា និងការបង្រៀនសៀវភៅពុម្ពថ្មីៗ។

ក្នុងនាមគណៈគ្រប់គ្រង បុគ្គលិកអប់រំ និងគ្រូឧទ្ទេស នៃវិទ្យាស្ថានជាតិអប់រំទាំងអស់ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅជាទីបំផុត ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ប្អូនៗនិស្សិត

គរុនិស្សិត និងគរុសិស្ស ដែលមានបំណងចង់បន្តការសិក្សានៅវិទ្យាស្ថានជាតិអប់រំ ដើម្បីទទួលបាន អាជីពជាអ្នកគ្រប់គ្រងអប់រំ ជាអធិការអប់រំ និងជាគ្រូបង្រៀនប្រកបដោយគុណវុឌ្ឍិ និងមានការ ទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាពីរដ្ឋាភិបាលកម្ពុជា។ យើងក៏សូម ស្វាគមន៍ផងដែរចំពោះដៃគូអភិវឌ្ឍនានា ដែលមានបំណងសហការជាមួយវិទ្យាស្ថានជាតិអប់រំ ក្នុងការរួមចំណែកលើកកម្ពស់ធនធានអប់រំនៅកម្ពុជា។

## ៤.៣. គន្លឹះនៃភាពជោគជ័យ (លទ្ធផលដែលសម្រេចបាន)

វជអ បានអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុនៅទីតាំងវិទ្យាសាស្ត្ររបស់ខ្លួនផ្ទាល់។ វិទ្យាស្ថានក៏ផ្តល់ នូវការគ្រប់គ្រងថវិកាឯកជន ដែលទទួលបានពីវគ្គសិក្សាឯកជន ដែលអនុម័តដោយក្រសួង អប់រំ។ ហេតុនេះ ប្រព័ន្ធគណនេយ្យ ក៏អាចគ្រប់គ្រងប្រាក់ចំណូលទាំងនោះបានផងដែរ។

វេទិកាអនឡាញ ត្រូវបានបង្កើតឡើងនៅទូទាំងបរិវេណវិទ្យាស្ថានទាំងមូល ដោយមាន វិធីសាស្ត្របង្រៀនតាមអនឡាញថ្មីៗ ដោយប្រើប្រាស់កម្មវិធីអនឡាញឥតគិតថ្លៃ Google, G-Suite។ គណៈគ្រប់គ្រង និងសាស្ត្រាចារ្យ ទទួលបានការបណ្តុះបណ្តាលពីរបៀបប្រើកម្មវិធី G-Suite ជាពិសេសប្រើ Google Classroom សម្រាប់ការគ្រប់ឯកសារ និងកម្មវិធី Google Meet សម្រាប់ប្រាស្រ័យទាក់ទង និងការរៀនតាមអនឡាញ។ អ្នកក៏អាចបង្កើត និងតាមដាន បង្រៀន និងណែនាំរួមបញ្ចូលគ្នាជាមួយគរុនិស្សិត និងបុគ្គលិកនៅ វជអ បានផងដែរ។ វិទ្យាស្ថាននេះ ក៏ បានអនុវត្តការអភិវឌ្ឍសមត្ថភាពក្នុងសំណេរសៀវភៅពុម្ព ក៏ដូចជាការវាយតម្លៃលើសូចនាករ រចនាសម្រាប់គណិតវិទ្យា និងវិទ្យាសាស្ត្រ។ បន្ថែមលើនេះ គ្រូបង្រៀន ICT ទទួលបានការគាំទ្រច្រើនជាងមុនពីបុគ្គលិកបច្ចេកទេស។

ជាងនេះទៅទៀត បុគ្គលិកបច្ចេកទេសរបស់ វជអ ក៏បានផ្តល់ការបណ្តុះបណ្តាលលើ "ការ គ្រប់គ្រងការបង្រៀន និងការរៀនដោយប្រើកម្មវិធី G-Suite" ផងដែរ។

## ៤.៤. សក្តានុពលសម្រាប់ការរៀនសូត្រ ឬការផ្ទេរបន្ត

វជអ គឺជាគ្រឹះស្ថានបណ្តុះបណ្តាលចាស់ជាងមួយ ដែលមានអាយុកាលប្រហែល 103 ឆ្នាំ ហើយខ្លួនមានទីតាំងបរិវេណវិទ្យាស្ថានធំ ដែលមានទីតាំងនៅកណ្តាលរាជធានីភ្នំពេញ។ វជអ គឺជា គ្រឹះស្ថានឧត្តមសិក្សាពិសេសមួយ ដែលមានតួនាទី និងទំនួលខុសត្រូវក្នុងការបណ្តុះបណ្តាល គ្រូបង្រៀន និងអ្នកគ្រប់គ្រងអប់រំ។ វិទ្យាស្ថានមានបុគ្គលិកចំនួន 237 នាក់ រួមទាំងគ្រូឧទ្ទេស ចំនួន 170 នាក់ ក្នុងចំណោមនោះ 10 នាក់ មានសញ្ញាបត្របណ្ឌិត ហើយ 137 នាក់ទៀត មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់។ គណៈគ្រប់គ្រង និងគ្រូឧទ្ទេសភាគច្រើនអាចនិយាយភាសា អង់គ្លេសបាន និងអាចប្រើប្រាស់កុំព្យូទ័របានល្អ។ គ្រូឧទ្ទេសដែលចេះនិយាយភាសាអង់គ្លេសភាគ ច្រើន វាយតម្លៃគរុនិស្សិតពាក់ព័ន្ធនឹងចំណេះដឹង បទពិសោធ វិធីសាស្ត្របង្រៀន និងការជំរុញ លើកទឹកចិត្តការសិក្សា។

បន្ថែមលើនេះ គ្រប់សាស្ត្រាចារ្យនិងបុគ្គលិកដែលទទួលបានការបណ្ដុះបណ្ដាលក្នុងវិធីសាស្ត្របង្រៀនថ្មីៗ ដូចជា គំរូ 5Es ការដោះស្រាយបញ្ហា ការរៀនសម្របខ្លួន ការរៀនបែបស្ថាបនានិយម ការរៀនផ្អែកតាមរយៈការចោទសួរ ។ល។ និង ។ល។ វិធីសាស្ត្រទាំងអស់នេះត្រូវបានរំពឹងថានឹងត្រូវយកមកអនុវត្តនៅតាមវិទ្យាល័យនៅទូទាំងប្រទេស។

## ៤.៤. ព័ត៌មានបន្ថែម

ដោយមើលឃើញពីវឌ្ឍនភាពនៃ វជអ ជាពិសេសពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាពរបស់គ្រូឧទ្ទេស និងបុគ្គលិក ក៏មានការកែលម្អគួរឱ្យកត់សម្គាល់ ហើយក្រសួងអប់រំ យុវជន និងកីឡា ក៏បានផ្តល់អាទិភាពដល់កំណែទម្រង់គ្រូបង្រៀនផងដែរ។ គណៈគ្រប់គ្រង កំពុងធ្វើការយ៉ាងសកម្មជាមួយថ្នាក់ដឹកនាំមកពី ក្រ អយក ដែលមានន័យថា មានការបង្កើតនូវភាពជាដៃគូរឹងមាំមួយ។ វជអ បានបង្កើតកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក ហើយវិទ្យា-ស្ថានក៏ទទួលបានការគាំទ្រពីដៃគូដទៃផ្សេងទៀត ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អង្គការ JICA ដែលបានជួយពង្រឹងសមត្ថភាព និងវិសាលភាពរបស់ខ្លួន អង្គការ CDPF ដែលបានជួយពង្រឹងសមត្ថភាពនៅកម្រិតថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការធ្វើផែនការ និងការគ្រប់គ្រង អង្គការ UNICEF ដែលបានជួយដល់ការធ្វើអធិការកិច្ចការនៅតាមសាលារៀន និងវិធីសាស្ត្រវាយតម្លៃ និងគម្រោង BALANCE ដែលបានជួយដល់ការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុ។

## ៤.៥. ព័ត៌មានលម្អិតទំនាក់ទំនង

វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋាន៖ ផ្លូវ 123 កែងមហាវិថីនរោត្តម និងមហាវិថីសីហនុ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ទូរសព្ទ៖ (855) 23 215 584

គេហទំព័រ៖ www.nie.edu.kh

អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ, វជអ, គម្រោង BALANCE លោក
សៀង វាសនា មន្ត្រី

ទូរសព្ទ៖ (+855) 12 337 246

អ៊ីម៉ែល៖ sieng.veasna@nie.edu.kh

គេហទំព័រ៖ www.nie.edu.kh

# សាកលវិទ្យាល័យជាតិគ្រប់គ្រង

# ៥
# សាកលវិទ្យាល័យជាតិគ្រប់គ្រង

## ប្រាក់រង្វាន់លើកទឹកចិត្តផ្អែកតាមសកម្មភាពការងារសម្រាប់ការបង្កើនផលិតភាព និងការកសាងមុខមាត់របស់សាកលវិទ្យាល័យ៖ ករណីសាកលវិទ្យាជាតិគ្រប់គ្រង (NUM)

### ៥.១. សាវតារ

សាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ1983 ហើយត្រូវបានទទួលស្គាល់ជាសាកលវិទ្យាល័យរដ្ឋឈានមុខគេមួយនៅក្នុងផ្នែកអប់រំធុរកិច្ច និងគ្រប់គ្រង នៅក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ2005 សាកលវិទ្យាល័យនេះត្រូវបានទទួលស្គាល់ជាស្ថាប័នគ្រប់គ្រងមិនរកប្រាក់កម្រៃរបស់រដ្ឋ។ ចក្ខុវិស័យរបស់ NUM គឺ "ដើម្បីក្លាយខ្លួនជាសាកលវិទ្យាល័យស្រាវជ្រាវឈានមុខគេនៅក្នុងការធ្វើឱ្យប្រសើរឡើងនូវសហគ្រិនភាព និងនវានុវត្តន៍"។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ សាកលបានធ្វើការវិនិយោគធនធានលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍបុគ្គលិកដែលផ្តល់នូវមជ្ឍដ្ឋានសិក្សាដែលមានភាពងាយស្រួល។ មិនត្រឹមតែបានធ្វើទំនើបកម្មលើបរិក្ខារ និងអគារប៉ុណ្ណោះទេ ប៉ុន្តែខ្លឹមសារនៃកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ ក៏ត្រូវតែធ្វើកែលម្អដើម្បីបំពេញតាមតម្រូវការនៃការប្រែប្រួលវិសាលភាពនៃការអប់រំ និងពាណិជ្ជកម្មផងដែរ។ បេសសកម្មរបស់សាកលវិទ្យាល័យគឺ "ដើម្បីបណ្តុះអ្នកដឹកនាំ អ្នកគ្រប់គ្រង និងសហគ្រិនដែលមានគំនិតច្នៃប្រឌិតសម្រាប់សង្គមជាតិ"។ ដើម្បីសម្រេចបានចក្ខុវិស័យ និងបេសសកម្មរបស់ខ្លួន NUM មានការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្នុងការជំរុញ និងការពារគុណតម្លៃស្នូលដែលមានស្រាប់ ធ្វើជាមូលដ្ឋានគ្រឹះសម្រាប់វប្បធម៌របស់ខ្លួន៖ គុណភាព ការស្រាវជ្រាវ នវានុវត្តន៍ ទីតាំងបរិវេណបៃតង និងនិស្សិត។

សាកលវិទ្យាល័យគឺជាគ្រឹះស្ថានឈានមុខគេនៅក្នុងផ្នែកសេដ្ឋកិច្ច ធុរកិច្ច ហិរញ្ញវត្ថុ និងការគ្រប់គ្រងការអប់រំនៅទូទាំងប្រទេស ហើយបានផលិតនិស្សិតបញ្ញវន្តថ្មីៗ អ្នកជំនាញ និងសហគ្រិនជោគជ័យជាច្រើនសម្រាប់សង្គមកម្ពុជា។ NUM បានដើរតួនាទីយ៉ាងសំខាន់បំផុតនៅក្នុងការចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍធនធានមនុស្សសម្រាប់ប្រទេសកម្ពុជា។ ចាប់តាំងពីការ

បង្កើតសាកលវិទ្យាល័យ NUM ក្នុងឆ្នាំ1983 រហូតដល់ឆ្នាំសិក្សា 2019-2020 នេះ សាកលវិទ្យាល័យ NUM មាននិស្សិតបញ្ចប់ការសិក្សាចំនួន 51,887 នាក់ នៅគ្រប់កម្រិតសិក្សាទាំងអស់។ ក្នុងចំណោមនោះ មាននិស្សិត 6,746 នាក់ ជានិស្សិតអាហារូបករណ៍ ហើយ 45,141 នាក់ទៀត ជានិស្សិតបង់ថ្លៃ។ បច្ចុប្បន្ននេះ មាននិស្សិតចំនួន 14,600 នាក់ ដែលបានចុះឈ្មោះសិក្សាក្នុងមុខវិជ្ជាខុសៗគ្នាថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សាថ្នាក់បណ្ឌិត ដែលមានមហាវិទ្យាល័យចំនួន ៨។

*ប្រភេទនៃឧត្តមានុវត្តន៍៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ប្រាក់រង្វាន់លើកទឹកចិត្ត និងផលិតភាព*

## ៥.២. ព័ត៌មានលម្អិតអំពីឧត្តមានុវត្តន៍

រចនាសម្ព័ន្ធគ្រប់គ្រងរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រងមានដូចជា ប្រធាន ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងសាកលវិទ្យាល័យ បុគ្គលិក សាស្ត្រាចារ្យពេញម៉ោងនិងសាស្ត្រាចារ្យកិច្ចសន្យាជាជនជាតិខ្មែរ និងបរទេសដែលមានបុគ្គលិកសរុបចំនួន 396នាក់។

ក្រុមប្រឹក្សាភិបាល គឺជាអង្គភាពធ្វើសេចក្តីសម្រេចចិត្តធំជាងគេបង្អស់របស់សាកលវិទ្យាល័យ NUM។ អង្គភាពនេះទទួលខុសត្រូវជារួមលើការគ្រប់គ្រងហិរញ្ញវត្ថុ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យ។ ក្រុមប្រឹក្សាភិបាលអនុម័តលើផែនការយុទ្ធសាស្ត្រ (ផែនការអភិវឌ្ឍន៍រយៈពេល 3 ឆ្នាំ) សៀវភៅណែនាំស្តីពីហិរញ្ញវត្ថុ ថវិកាប្រចាំឆ្នាំ ក៏ដូចជារបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំផងដែរ។

សាកលវិទ្យាធិការ និងគណៈគ្រប់គ្រង ទទួលខុសត្រូវសម្រាប់ការដឹកនាំការអភិវឌ្ឍផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យជាតិគ្រប់គ្រង។ បុគ្គលទាំងនេះ ក៏ត្រូវទទួលខុសត្រូវលើការធ្វើសេចក្តីសម្រេចចិត្តប្រតិបត្តិការផងដែរ។ ពួកគាត់នឹងធ្វើការអនុវត្តថវិកាប្រចាំឆ្នាំ ត្រួតពិនិត្យសកម្មភាពហិរញ្ញវត្ថុរបស់សាកលវិទ្យាល័យឡើងវិញ និងធ្វើការរាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ NUM។

គណៈគ្រប់គ្រង ក៏មានទំនួលខុសត្រូវក្នុងការធានាថា ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងមានដំណើរការដោយរលូន ហើយរាល់លក្ខខណ្ឌតម្រូវនៃការរាយការណ៍និងលក្ខខន្តិកៈរបស់សាកលវិទ្យាល័យត្រូវបានអនុវត្តពេញលេញ។

ប្រធានអង្គភាពហិរញ្ញវត្ថុ និងបុគ្គលិកហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវប្រតិបត្តិការ និងការថែទាំប្រព័ន្ធហិរញ្ញវត្ថុ ក៏ដូចជាសម្រាប់ការរាយការណ៍លើសកម្មភាពហិរញ្ញវត្ថុ និងស្ថានភាពហិរញ្ញវត្ថុរបស់សាកលវិទ្យាល័យផងដែរ។ អង្គភាពហិរញ្ញវត្ថុ អនុវត្តនីតិវិធីហិរញ្ញវត្ថុដែលបានអនុម័តរួច។

អង្គភាពហិរញ្ញវត្ថុ ត្រូវធ្វើការរៀបចំឱ្យបានល្អ ដែលមានរចនាសម្ព័ន្ធរាយការណ៍ច្បាស់លាស់។ រាល់បុគ្គលិកទាំងអស់ ត្រូវមានបំណែងចែកការងារច្បាស់លាស់ដែលពន្យល់ពីទំនួលខុសត្រូវរបស់បុគ្គលម្នាក់ៗ។

ការដែលរំពឹងឱ្យក្រុមប្រឹក្សាភិបាល ឬសាកលវិទ្យាធិការធ្វើការសម្រេចចិត្តគ្រប់រឿង និងអនុម័តរាល់ប្រតិបត្តិការសាច់ប្រាក់ទាំងអស់ មិនមែនជារឿងល្អនោះទេ។ ហេតុនេះ សាកលវិទ្យាល័យនឹងធ្វើប្រគល់សិទ្ធិដល់មន្ត្រីសមស្របរបស់ HEI ដើម្បីអនុម័តលើប្រតិបត្តិការសាច់ប្រាក់ឱ្យមានប្រសិទ្ធភាព និងមានការត្រួតពិនិត្យដោយគោលនយោបាយបានគ្រប់គ្រាន់។

ជាទូទៅ NUM តែងរៀបចំផែនការយុទ្ធសាស្ត្រដើម្បីពន្យល់ពីចក្ខុវិស័យ និងបេសកកម្មរបស់សាកលវិទ្យាល័យ គោលដៅសម្រាប់រយៈពេល 5 ឆ្នាំទៅមុខ និងយុទ្ធសាស្ត្រដែលបានជ្រើសរើសរួចត្រូវការសម្រេចឱ្យបាន។

ផែនការយុទ្ធសាស្ត្រ ត្រូវមានការគាំទ្រដោយផែនការហិរញ្ញវត្ថុយុទ្ធសាស្ត្របន្ថែម។

NUM រៀបចំថវិកាប្រចាំឆ្នាំរួមបញ្ចូលគ្នាសម្រាប់ឆ្នាំសារពើពន្ធនីមួយៗ។ ថវិកាជួយដឹកនាំសាកលវិទ្យាល័យ ដើម្បីឱ្យមូលនិធិនោះត្រូវបានប្រើប្រាស់តាមរបៀបដែលមានប្រសិទ្ធភាពបំផុត ហើយវាក៏ជួយធានាថា នឹងមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការចំណាយប្រាក់ក្នុងឆ្នាំនីមួយៗ។ ថវិកាពឹងផ្អែកលើផែនការយុទ្ធសាស្ត្រ ក៏ដូចជាផែនការហិរញ្ញវត្ថុយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍រយៈពេល 3 ឆ្នាំ ផងដែរ។

## ៥.៣. ឥស្សរភាពនៃភាពជោគជ័យ (លទ្ធផលដែលសម្រេចបាន)

ក្នុងនាមជាសាកលវិទ្យាល័យគ្រប់គ្រងដែលមិនរកប្រាក់កម្រៃរបស់រដ្ឋ NUM គឺជាសាកលវិទ្យាល័យទំនុកបម្រុងហិរញ្ញវត្ថុដោយខ្លួនឯង។ ប្រាក់ចំណូលរបស់សាកលវិទ្យាល័យនេះ ភាគច្រើនបានមកពីថ្លៃសិក្សារបស់និស្សិត (ប្រមាណជា 90%) ហើយប្រាក់ដែលសេសសល់ដទៃទៀត បានមកពីរដ្ឋាភិបាល។ ថវិការបស់ NUM នៅបន្តមានស្ថេរភាពដដែលក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបានអនុម័យឱ្យប្រើប្រាស់តាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS)។ បន្ថែមលើនេះ ប្រព័ន្ធ E-Leaning ត្រូវបានណែនាំឱ្យប្រើប្រាស់ភ្លាមៗបន្ទាប់ការផ្ទុះជំងឺកូវីដ-19។ បន្ទាប់ពីការអនុវត្តប្រព័ន្ធ MIS ចូលក្នុងប្រព័ន្ធរបស់សាកលវិទ្យាល័យនេះ NUM បានសម្រេចនូវការកែលម្អជាច្រើន ដូចជា៖

- តម្លាភាព និងការកែលម្អលើការគ្រប់គ្រងហិរញ្ញវត្ថុ។
- ការកែលម្អយ៉ាងច្រើនលើបរិមាណ និងគុណភាពនៃការចុះឈ្មោះចូលរៀន។
- នវានុវត្តន៍នៅក្នុងលំហបរិស្ថានមេត្រីសម្រាប់បុគ្គលិក។
- ធ្វើបច្ចុប្បន្នភាពជាប្រចាំឆ្នាំលើគោលវិធីនៃការបង្រៀន។
- ការកែលម្អលើការប្រាស្រ័យទាក់ទងជាមួយនិស្សិត និងកិច្ចការ។
- ការកំណត់ច្បាស់ៗ និងការបែងចែកភារកិច្ច ទំនួលខុសត្រូវ និងសិទ្ធិអំណាច។

សាកលវិទ្យាល័យបង្កើតកម្រងសិទ្ធិអំណាចដែលបានប្រគល់ជូន ដើម្បីបង្ហាញច្បាស់ថានរណាមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត ធ្វើការចំណាយ និងចុះហត្ថលេខាលើឯកសារផ្លូវច្បាប់ជំនួសមុខឱ្យ HEI។

កម្រងសិទ្ធិអំណាចនេះ បង្ហាញពីដែនកំណត់ ឬលក្ខខណ្ឌណាមួយដែលអនុវត្តចំពោះសិទ្ធិអំណាចដែលបានប្រគល់រួច។ នេះនឹងរួមបញ្ចូលចំនួនសិទ្ធិអតិបរមារបស់មន្ត្រីម្នាក់ៗក្នុងការអនុម័តលើលក្ខខណ្ឌទាំងនេះផងដែរ ហើយក៏អាចកំណត់ពីការអនុម័តលើប្រភេទនៃការចំណាយ ឬសម្ភារៈរូបវន្តជាក់លាក់ ឬដេប៉ាតឺម៉ង់នៅក្នុង HEI។

កម្រងសិទ្ធិដែលបានផ្តល់ជូន ត្រូវលើកឡើងពីការយល់ព្រម និងទំនួលខុសត្រូវសម្រាប់កិច្ចការដែលរួមបញ្ចូលនូវចំណុចដូចខាងក្រោម៖

- ការអនុម័តលើសំណើទិញ និងការបញ្ជាទិញទំនិញនិងសេវាកម្ម
- ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនផ្គត់ផ្គង់
- ការចុះកិច្ចសន្យា និងកិច្ចសន្យាហិរញ្ញប្បទានជាមួយម្ចាស់ជំនួយ និងទីភ្នាក់ងារផ្តល់មូនិធិ
- ការអនុម័តយល់ព្រមលើការទូទាត់ និងសក្ខីបត្រទូទាត់ប្រាក់
- ការអនុម័តលើការទូទាត់ប្រាក់វេជ្ជទេយ្យ
- ការអនុម័តលស់សក្ខីបត្រប្រាក់ចំណូល និងសក្ខីបត្រទទួលប្រាក់
- ការអនុម័តលស់សក្ខីបត្រទិន្នានុប្បវត្តិ
- ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ពាក់ព័ន្ធនឹងហិរញ្ញវត្ថុទៅកាន់ស្ថាប័នខាងក្រៅ
- ការបើក និងការបិទគណនេយ្យធនាគារ
- ប្រតិបត្តិការធនាគាររួមបញ្ចូលនូវការផ្ទេរប្រាក់ឆ្លងគណនេយ្យ ប្រាក់បៀវត្សរ៍ ការបើកគណនីសន្សំ និងការគណនីដាក់ប្រាក់មានកាលកំណត់
- ការបង្កើតគណនីប្រាក់វេជ្ជទេយ្យ
- ការជម្រះបញ្ជីទ្រព្យសកម្ម។

## ៥.៤. សក្តានុពលសម្រាប់ការរៀនសូត្រ ឬការផ្ទេរបន្ត

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ NUM គប្បីធ្វើបច្ចុប្បន្នភាពបន្ថែមទៀត។ ប្រព័ន្ធ E-Learning នៅបន្តដាក់ឱ្យប្រើប្រាស់ និងមានការពេញនិយមក្នុងចំណោមនិស្សិត និងសាស្ត្រាចារ្យ បន្ទាប់ការផ្ទុះការឆ្លងរាលដាលនៃជំងឺកូវីដ-19។ សក្តានុពលសម្រាប់ការរៀន និងការផ្ទេរបន្តរួមមាន៖

- ការគ្រប់គ្រងហិរញ្ញវត្ថុ
- ការបង្កើតកម្មវិធីថ្មីសម្រាប់ការចុះឈ្មោះនិស្សិត
- បរិមាណ និងគុណភាពនៃការចុះឈ្មោះចូលរៀន
- លំហាមេត្រីបរិស្ថាន
- កម្មវិធីអន្តរជាតិ និងកិច្ចសហប្រតិបត្តិការ
- គោលវិធីនៃការបង្រៀន

- ការប្រាស្រ័យទាក់ទងជាមួយនិស្សិត និងកិច្ចការនិស្សិត
- តួនាទី ទំនួលខុសត្រូវ និងសិទ្ធិអំណាចសម្រាប់អង្គភាពនីមួយៗ ។ល។

## ៥.៦. ព័ត៌មានបន្ថែម

រាល់ព័ត៌មានទាំងអស់អាចទទួលបានតាមរយៈផែនការយុទ្ធសាស្ត្រឆ្នាំ2019-2023 របស់សាកលវិទ្យាល័យជាតិគ្រប់គ្រង សៀវភៅបោះពុម្ពផ្សាយរបស់ NUM គេហទំព័ររបស់ NUM ក៏ដូចជាការអនុវត្តប្រចាំឆ្នាំផងដែរ។

## ៥.៧. ព័ត៌មានលម្អិតទំនាក់ទំនង

**សាកលវិទ្យាល័យជាតិគ្រប់គ្រង**

អាសយដ្ឋាន៖ ផ្លូវ96 គ្រីស្តូភើ ហូវ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

**អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ, សាកលវិទ្យាល័យជាតិគ្រប់គ្រង, គម្រោង BALANCE**

បណ្ឌិត លី សុខហេង សាកលវិទ្យាធិការរង ទូរសព្ទ៖

( +855 ) 12 445 727

អ៊ីម៉ែល៖ lysokheng@num.edu.kh

គេហទំព័រ៖ https://num.edu.kh

# សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ

# ៦
# សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ

## ប្រាក់ខ្ទាន់លើកទឹកចិត្តផ្អែកតាមសកម្មភាពការងារសម្រាប់ការបង្កើនផលិតភាព និងការកសាងមុខមាត់របស់សាកលវិទ្យាល័យ៖ ករណីសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ (សហសត)

### ៦.១. សាវតារ

សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ (ហៅកាត់ថា សហសត) គឺជាសាកលវិទ្យាល័យរដ្ឋមួយដែលបានបង្កើតឡើងដោយអនុក្រឹត្យលេខ 24 អនក្រ.បក ចុះថ្ងៃទី5 ខែកុម្ភៈ ឆ្នាំ2016 និងចាប់ផ្តើមបើកសម្ពោធជាផ្លូវការនៅថ្ងៃទី11 ខែកុម្ភៈ ឆ្នាំ2016 ដោយសារកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា (ក្រ អយក)។ ចក្ខុវិស័យរបស់ សហសត គឺដើម្បីក្លាយខ្លួនជាមជ្ឈមណ្ឌលអប់រំនិងបណ្តុះបណ្តាលឈានមុខគេក្នុងផ្នែកវិទ្យាសាស្ត្រ និងអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា។ ក្នុងស្មារតីនេះ សហសត ផ្តល់ជូននូវការអប់រំរដ្ឋ ការស្រាវជ្រាវ ការអភិវឌ្ឍសហគមន៍ និងសេវាសង្គម ដោយផ្តោតសំខាន់លើវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។ សហសត ផ្តល់នូវការបណ្តុះបណ្តាលវិជ្ជាជីវៈ-TVET កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រ ដែលមានមហាវិទ្យាល័យចំនួន 4 វិទ្យាស្ថានចំនួន 3 និងកម្មវិធីចំនួន 22។ សហសត មានអាជ្ញាប័ណ្ណពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបើកកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅក្នុងឆ្នាំ2020 ហើយខ្លួនក៏បានបើកដំណើរការថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកកែច្នៃចំណីអាហារ និងនវានុវត្តន៍នៅដើមឆ្នាំ2021នេះផងដែរ។ សាកលវិទ្យាល័យមានគោលបំណងក្នុងការផ្តល់ចំណេះដឹងឯកទេស និងជំនាញអនុវត្ត ក៏ដូចជាការផ្តល់ការអប់រំ ការស្រាវជ្រាវ សេវាសង្គមនិងការអភិវឌ្ឍផងដែរ។ សាកលវិទ្យាល័យនេះមានវិទ្យាស្ថានឧត្តមសិក្សាពិសេសមួយនៅក្នុងប្រទេសកម្ពុជា ដោយផ្តោតសំខាន់លើគុណភាពអប់រំ។ ជាតុស្តូលនៃគោលបំណងរបស់ សហសត មានដូចជា (1) ដើម្បីក្លាយជាគ្រឹះស្ថានឧត្តមសិក្សាគំរូក្នុងផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៅក្នុងប្រទេសកម្ពុជា (2) ដើម្បីកសាងចំណេះដឹង ចំណេះធ្វើ និងនវានុវត្តន៍របស់និស្សិត

ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍសង្គមជាតិ និង (3) ដើម្បីបណ្តុះបណ្តាលនិស្សិតឱ្យទទួលបានជំនាញការងារដែលចាំបាច់ ដើម្បីរកបានការងារល្អ និងដើម្បីជួយដល់ជីវិតសិក្សារបស់ពួកគេ។

*ប្រភេទនៃឧត្តមានុវត្តន៍៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ប្រាក់រង្វាន់លើកទឹកចិត្ត និងផលិតភាព*

## ៦.២. ព័ត៌មានលម្អិតអំពីឧត្តមានុវត្តន៍

គ្រឹះស្ថានឧត្តមសិក្សា គឺជាស្ថាប័នផ្តល់សេវា ដែលតាមរយៈនេះ និយោជិតគឺជាធនធានដ៏សំខាន់សម្រាប់ផ្តល់សេវាកម្មដល់និស្សិត និងភាគីដែលពាក់ព័ន្ធទាំងអស់។ បុគ្គលិកអប់រំ បុគ្គលិកគ្រប់គ្រង និងសាស្ត្រាចារ្យ គឺជាតួអង្គសំខាន់នៅក្នុងការដឹកនាំសកម្មភាពប្រតិបត្តិការរបស់ស្ថាប័ន។ ការគ្រប់គ្រង និងការអនុវត្តជាផ្លូវការនូវប្រាក់រង្វាន់លើកទឹកចិត្តផ្អែកតាមសកម្មភាពការងារ រួមជាមួយសូចនាកររង្វាស់វែង អាចបង្កើនផលិតភាពរបស់ស្ថាប័នបាន។ សហសត អនុវត្តប្រាក់រង្វាន់លើកទឹកចិត្តផ្អែកតាមសកម្មភាពការងារ ដោយប្រើប្រព័ន្ធនៅក្នុងថ្នាក់រៀន និងប្រព័ន្ធអនឡាញ ដើម្បីអាចវាយតម្លៃបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ បុគ្គលិកអប់រំ ត្រូវធ្វើការវាយតម្លៃផ្អែកលើសមាសធាតុវិន័យ និងសកម្មភាពការងារប្រចាំខែ ក៏ដូចជាសមាសធាតុលទ្ធផល ដែលបញ្ជាក់បន្ថែមលើការបំពេញការងារ ដំណើរការការងារ និងគុណភាពបុគ្គលិកលក្ខណៈផងដែរ។ សាស្ត្រាចារ្យត្រូវបានវាយតម្លៃដោយផ្អែកលើសមិទ្ធផលរបស់ពួកគេនៅក្នុងឆមាសនីមួយៗ យោងតាមក្របខណ្ឌគុណវុឌ្ឍិជាតិ (NQF) ដែលចេញដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក)។ នៅ សហសត សាស្ត្រាចារ្យត្រូវការបំពេញតាមតម្រូវការស្របទៅតាមសូចនាករបំពេញការងារ ដែលមានចែងនៅក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិ ក៏ដូចជាដើម្បីអនុវត្តតាមគោលនយោបាយសិក្សាធិការរបស់សហសត ផងដែរ។ សាស្ត្រាចារ្យគ្រប់ប្រភេទ ទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមចំណែកវិជ្ជមានលើសកម្មភាពការងាររបស់សាកលវិទ្យាល័យក្នុងនាមជាស្ថាប័នមួយ។ វិធីគ្រប់គ្រងគ្រឹះស្ថានអប់រំប្រកបដោយជោគជ័យ គឺការទទួលស្គាល់ដៃគូពីខាងក្រៅ។ សមិទ្ធផលនៃសូចនាករបំពេញការងាររបស់បុគ្គលិក សហសត អាចលើកមុខមាត់សាកលវិទ្យាល័យ ទាំងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ ឧទាហរណ៍ សាស្ត្រាចារ្យមួយរូប ត្រូវបានផ្តល់ឱកាសឱ្យសិក្សាថ្នាក់ បណ្ឌិត នៅសាកលវិទ្យាល័យហុងកុង ក្រោយពីមានការវាយតម្លៃខ្ពស់ចំពោះសកម្មភាពការងាររបស់គាត់ដោយឆ្លុះបញ្ចាំងពីការរួមចំណែកដល់គុណភាពអប់រំនិស្សិត និងមុខមាត់របស់ សហសត។ សាស្ត្រាចារ្យប្រាំរូបផ្សេងទៀត ក៏ទទួលបានការគាំទ្រឱ្យសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យហុងកុង បន្ទាប់ពីលទ្ធផលផ្អែកលើការបំពេញការងារមានភាពល្អប្រសើរ។

## ៦.៣. ឥស្សរតាងនៃភាពជោគជ័យ (លទ្ធផលដែលសម្រេចបាន)

ការអនុវត្តការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តផ្អែកលើសកម្មភាពការងារតាមអនឡាញនៅ សហសត បានឈានមួយជំហានទៅមុខទៀត ឆ្ពោះទៅរកការធ្វើទំនើបកម្មពាក់ព័ន្ធនឹងការ

គ្រប់គ្រងបុគ្គលិកនៅក្នុងប្រទេសឥណ្ឌូនេស៊ី។ ចំណុចនេះបានក្លាយជាមធ្យោបាយសម្រាប់បង្កើនផលិតភាពស្ថាប័នសម្រាប់បុគ្គលិកអប់រំ ផ្អែកលើវិន័យ និងសមិទ្ធផលបំពេញការងារ ដែលត្រូវបានវាយតម្លៃរៀងរាល់ខែ និងផ្តោតសំខាន់លើការបំពេញការងារ ដំណើរការការងារ និងគុណភាពបុគ្គលិកលក្ខណៈ។ បុគ្គលិកអប់រំអាចអនុវត្តតាមវិធាននេះ បំពេញកិច្ចការស្របទៅតាមស្តង់ដាជាក់លាក់ បានត្រឹមត្រូវ និងទាន់ពេលវេលា ហើយមានទំនួលខុសត្រូវក្នុងការផ្តល់សេវាកម្មល្អប្រសើរដល់និស្សិត។ ជាងនេះទៅទៀត សហគមន៍សិក្សាធិការទទួលប្រយោជន៍ពីប្រព័ន្ធដែលបានអនុវត្តនេះ។ បុគ្គលិកអប់រំ ត្រូវបានវាយតម្លៃមួយខែម្តង ចំណែកឯសាស្ត្រាចារ្យត្រូវបានវាយតម្លៃមួយឆមាសម្តង ពាក់ព័ន្ធនឹងលក្ខខណ្ឌវិនិច្ឆ័យបំពេញការងារដែលរៀបរាប់នៅខាងលើ ផ្អែកលើប្រភេទសាស្ត្រាចារ្យ។ ការវាយតម្លៃលើសកម្មភាពការងាររបស់សាស្ត្រាចារ្យនៅតែត្រូវពឹងផ្អែកលើក្របខណ្ឌគុណវុឌ្ឍិជាតិ និងគោលនយោបាយសិក្សាធិការរបស់ សហសតដដែល។ សាស្ត្រាចារ្យដែលផ្តោតសំខាន់លើសកម្មភាពបំពេញការងាររបស់សាកលវិទ្យាល័យក្នុងនាមជាស្ថាប័នមួយ (ដោយគិតពិចារណាពីការបង្កើនសកម្មភាពនិស្សិត/ការបំពេញការងារអន្តរជាតិ/ក្នុងតំបន់/ជាតិ ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ ដែលចុះផ្សាយនៅក្នុងទស្សនាវដ្តីស្រាវជ្រាវអន្តរជាតិដែលមានឈ្មោះល្បី) អាចបង្កើនចំណាត់ថ្នាក់សាកលវិទ្យាល័យនៅកម្រិតអន្តរជាតិ។ ការអនុវត្តការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តផ្អែកលើសកម្មភាពការងារតាមអនឡាញ មានផលវិជ្ជមានដល់ស្ថាប័ននេះ។ ភស្តុតាងនៃផលវិជ្ជមាននេះ រួមបញ្ចូលទាំងការបង្កើនចំនួននៃការទទួលស្គាល់នៅកម្រិតមូលដ្ឋាន កម្រិតតំបន់ កម្រិតជាតិ និងកម្រិតអន្តរជាតិ។

ឧទាហរណ៍ សាស្ត្រាចារ្យដែលបានលើកឡើងពីខាងលើ បានកែលម្អកិច្ចការ និងវិធីសាស្ត្របង្រៀនរបស់ពួកគេ ដើម្បីឈានដល់កម្រិតស្តង់ដាដែលត្រូវការ ហើយក៏ដើម្បីបង្កើនឥទ្ធិពលដល់បុគ្គលិក និងសាស្ត្រាចារ្យផ្សេងទៀត ឱ្យខិតខំធ្វើការងារ ដើម្បីទទួលបានប្រាក់រង្វាន់លើកទឹកចិត្តផ្អែកលើសកម្មភាពការងារ ដូចជាការផ្តល់ជំនួយឱ្យសិក្សាថ្នាក់បណ្ឌិត/ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ម៉ោងបង្រៀនបន្ថែម និងការដំឡើងឋានៈជាដើម។

## ៦.៤. សក្តានុពលសម្រាប់ការរៀនសូត្រ ឬការផ្ទេរបន្ត

ការអនុវត្តប្រាក់រង្វាន់លើកទឹកចិត្តផ្អែកលើសកម្មភាពការងារតាមអនឡាញនៅសាកលវិទ្យាល័យ មានការរីកសាយយ៉ាងទូលំទូលាយនៅតាមបណ្តាសាកលវិទ្យាល័យនានានៅជុំវិញពិភពលោក ហើយនេះជាវិធីសាស្ត្រសមស្របបំផុត ដោយគិតដល់ស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-19។ ប្រព័ន្ធនេះអនុវត្តវប្បធម៌ថ្មី ដោយបុគ្គលិករបស់សាកលវិទ្យាល័យ ទាំងសាស្ត្រាចារ្យទាំងបុគ្គលិកអប់រំ ត្រូវតម្រូវឱ្យសម្រេចគោលដៅរបស់ខ្លួនស្របតាមគោលដៅបំពេញការងារផ្អែកលើសូចនាករដែលបានកំណត់ទុកជាមុន។

## ៦.៥. ព័ត៌មានបន្ថែម

ដោយគិតពិចារណាពីវឌ្ឍនភាពដែល សហាសត បានសម្រេចបាន ជាពិសេសពាក់ព័ន្ធនឹងបុគ្គលិកអប់រំ និងសាស្រ្តាចារ្យ ដោយផ្តោតសំខាន់លើសាកលវិទ្យាល័យ ក្រ.អយក បានផ្តល់សិទ្ធិអំណាចដល់ សហាសត ដើម្បីបើកដំណើរការកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ហើយធនាគារពិភពលោក ក៏បានដាក់បញ្ចូល សហាសត ទៅក្នុងគម្រោងមួយពាក់ព័ន្ធនឹងប្រាក់ចំណូលវិទ្យាល័យ ដែលរកបានតាមរយៈការបណ្តុះបណ្តាលបំនិនជីវិតផងដែរ។

## ៦.៦. ព័ត៌មានលម្អិតទំនាក់ទំនង

**សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ**

អាសយដ្ឋាន៖ ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ប្រទេសកម្ពុជា

**អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុនៃសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ក្នុងគម្រោង BALANCE**

លោក ជិន យក់ សាកលវិទ្យាធិការរង

ទូរសព្ទ៖ (+855) 78 86 66 67

អ៊ីម៉ែល៖ chinypk168@gmail.com

គេហទំព័រ៖ www.uhst.edu.kh

# សាកលវិទ្យាល័យជាតិមានជ័យ

# ៧

# សាកលវិទ្យាល័យជាតិមានជ័យ

## ប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការជំរុញការលើកទឹកចិត្ត និងការងារបំពេញការងារ៖ មេរៀនពីសាកលវិទ្យាល័យជាតិមានជ័យ (ស.ជ.ម)

### ៧.១. សាវតារ

សាកលវិទ្យាល័យជាតិមានជ័យត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ2007ជាគ្រឹះស្ថានឧត្តមសិក្សារដ្ឋមិនរកប្រាក់កម្រៃដែលមានទីតាំងនៅក្រុងសិរីសោភ័ណខេត្តបន្ទាយមានជ័យ។ សាកលវិទ្យាល័យជាតិមានជ័យ (ស.ជ.ម) ត្រូវបានទទួលស្គាល់ជាផ្លូវការដោយក្រសួងអប់រំ យុវជន និងកីឡា ហើយជាគ្រឹះស្ថានឧត្តមសិក្សាសហអប់រំកម្ពុជា។ សាកលវិទ្យាល័យជាតិមានជ័យ (ស.ជ.ម) ផ្តល់ជូននូវវគ្គសិក្សា និងកម្មវិធីសិក្សា ដែលនាំទៅដល់សញ្ញាបត្រឧត្តមសិក្សាដែលមានការទទួលស្គាល់ជាផ្លូវការនៅក្នុងមុខវិជ្ជាសិក្សាជាច្រើន។ ស.ជ.ម ក៏បានផ្តល់នូវបរិក្ខារសិក្ខានិងក្រៅពីការសិក្សា និងសេវាកម្មដល់និស្សិតជាច្រើន រួមមានទាំងបណ្ណាល័យ ក៏ដូចជាសេវារដ្ឋបាលផងដែរ។

នៅថ្ងៃទី15 ខែធ្នូ ឆ្នាំ2020 សាកលវិទ្យាល័យនេះបានដាក់លិខិតស្នើសុំប្តូរឈ្មោះពីសាកលវិទ្យាល័យមានជ័យ (ស.ម.ជ) ទៅជាសាកលវិទ្យាល័យជាតិមានជ័យ (ស.ជ.ម) វិញ ដោយពុំមានផ្លាស់ប្តូរកម្មវិធីសិក្សារបស់ខ្លួនឡើយ។

*ប្រភេទនៃឧត្តមានុវត្តន៍៖ ការគ្រប់គ្រងហិរញ្ញវត្ថុដោយមានប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការលើកកម្ពស់ការជំរុញទឹកចិត្ត និងសកម្មភាពបំពេញការងារ*

### ៧.២. ព័ត៌មានលម្អិតអំពីឧត្តមានុវត្តន៍

ក្នុងនាមជាគ្រឹះស្ថានឧត្តមសិក្សារដ្ឋនៅក្នុងប្រទេសកម្ពុជា ដោយទទួលបានហិរញ្ញប្បទានពីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ស.ជ.ម គឺជាគ្រឹះស្ថានមួយដែលមានផ្តល់ជូននូវសេវាសិក្សាធិការ និងស្រាវជ្រាវ។ ក្នុងស្មារតីនេះ បុគ្គលិកសិក្សាធិការ និងបុគ្គលិកគ្រប់គ្រង ក៏ដូចជាសាស្ត្រាចារ្យ គឺជាធនធានមនុស្សដ៏សំខាន់ក្នុងការដំណើរការសកម្មភាពប្រតិបត្តិការរបស់គ្រឹះស្ថាននេះ។ បន្ថែមលើថ្លៃសិក្សា ក៏មានសកម្មភាពប្រតិបត្តិការប្រចាំថ្ងៃផងដែរ។ បុគ្គលិកខាងផ្នែករដ្ឋបាល ដែលជួយ

ដល់ការបង្រៀនបន្ថែម ទទួលបានប្រាក់ឧបត្ថម្ភគិតជាម៉ោង។

## ៧.៣. តស្តុតាងនៃភាពជោគជ័យ (លទ្ធផលដែលសម្រេចបាន)

តាមរយៈការអនុវត្ត ប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការជំរុញការលើកទឹកចិត្ត និងការងារបំពេញការងារ ឃើញថាមានលទ្ធផលល្អមួយចំនួននៅក្នុងការបង្រៀន និងបុគ្គលិករបស់យើង។ បុគ្គលិកចាស់មួយចំនួន សុខចិត្តចែករំលែកបទពិសោធបង្រៀនល្អផ្ទាល់ខ្លួនជាមួយបុគ្គលិកថ្មីនៅក្នុងមហាវិទ្យាល័យ និងព្រឹទ្ធបុរស ក៏ដូចជាបុគ្គលិកមហាវិទ្យាល័យផងដែរ។ ពួកគាត់សុទ្ធតែទទួលបានការលើកទឹកចិត្តឱ្យធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សារបស់ពួកគេដើម្បីបំពេញតាមតម្រូវការទីផ្សារនាពេលបច្ចុប្បន្ន។

## ៧.៤. សក្តានុពលសម្រាប់ការរៀនសូត្រ ឬការផ្ទេរបន្ត

តាមរយៈអភិបាលកិច្ចល្អ និងការគាំទ្រពីគម្រោងជាក់លាក់មួយចំនួន បុគ្គលិករបស់យើងខ្លះមានឱកាសល្អក្នុងការបង្កើនគុណវុឌ្ឍិ និងអភិវឌ្ឍសមត្ថភាពរបស់ពួកគេ តាមរយៈការបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ក៏ដូចជាបានចូលរួមក្នុងការបណ្តុះបណ្តាល និងសិក្ខាសាលាមួយចំនួនផងដែរ។

## ៧.៥. ព័ត៌មានលម្អិតទំនាក់ទំនង

**សាកលវិទ្យាល័យជាតិមានជ័យ**

អាសយដ្ឋាន៖ ផ្លូវជាតិលេខ5 សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា

**អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ, ស.ជ.ម, គម្រោង BALANCE**

លោក ង៉ោ ចន្ទនុរៈ ព្រឹទ្ធបុរសរង

ទូរសព្ទ៖ (+855) 78 85 86 87

អ៊ីម៉ែល៖

គេហទំព័រ៖ https://www.nmu.edu.kh/

# សាកលវិទ្យាល័យជាតិបាត់ដំបង

## (ស.ជ.ប.ដ)

# ៨

# សាកលវិទ្យាល័យជាតិបាត់ដំបង (ស.ជ.ប.ដ)

## ប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការជំរុញការលើកទឹកចិត្ត និងការងារ បំពេញការងារ៖ មេរៀនពីសាកលវិទ្យាល័យជាតិបាត់ដំបង (ស.ជ.ប.ដ)

### ៨.១. សាវតា

សាកលវិទ្យាល័យជាតិបាត់ដំបង (ស.ជ.ប.ដ) គឺជាសាកលវិទ្យាល័យរដ្ឋក្មេងជាងគេនៅកម្ពុជា ដោយបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៧ ហើយត្រូវបានប្តូរឈ្មោះជាសាកលវិទ្យាល័យជាតិបាត់ដំបង (ស.ជ.ប.ដ.) នៅក្នុងឆ្នាំ ២០២០ ដើម្បីផ្តល់ឱកាសដល់និស្សិតដែលរស់នៅក្នុងតំបន់ស្រុកស្រែចម្ការជាពិសេសនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា និងដើម្បីទទួលបានសេវាអប់រំឧត្តមសិក្សា ដើម្បីអភិវឌ្ឍអាជីពការងារផ្ទាល់ខ្លួនរបស់ពួកគេ ក៏ដូចជាសហគមន៍មូលដ្ឋានផងដែរ ហើយក្នុងពេលជាមួយគ្នានោះក៏កាត់បន្ថយគម្លាតចំណេះដឹងរវាងតំបន់ជនបទនិងក្រុងផងដែរ។ គោលដៅរបស់ ស.ជ.ប.ដ គឺដើម្បីអប់រំនិស្សិតឱ្យក្លាយជាអ្នកដឹកនាំនៅថ្ងៃអនាគតក្នុងវិស័យជាច្រើន តាមរយៈការផ្តល់នូវតុល្យភាពទ្រឹស្តី និងការអនុវត្តជាក់ស្តែង ស.ជ.ប.ដ បានធ្វើការយ៉ាងជិតស្និទជាមួយសហគមន៍មូលដ្ឋាន រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនសមាគមសាកលវិទ្យាល័យទាំងនៅក្នុងតំបន់ និងពិភពលោក។ សាកលវិទ្យាល័យនេះមានមហាវិទ្យាល័យចំនួនប្រាំ និងវិទ្យាស្ថានចំនួនមួយ៖ (១) មហាវិទ្យាល័យគ្រប់គ្រងធុរកិច្ច និងទេសចរណ៍ (២) មហាវិទ្យាល័យកសិកម្ម និងកែច្នៃចំណីអាហារ (៣) មហាវិទ្យាល័យសង្គមវិទ្យា និងអភិវឌ្ឍន៍សហគមន៍ (៤) មហាវិទ្យាល័យសិល្បៈមនុស្សសាស្ត្រ និងអប់រំ (៥) មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (៦) មហាវិទ្យាល័យភាសាបរទេស និងថ្នាក់ឧត្តម។ ស.ជ.ប.ដ មាននិស្សិតក្នុងស្រុកចំនួនជាង 3,500 នាក់ ដែលកំពុងសិក្សាក្នុងកម្មវិធីថ្នាក់ឧត្តម និងក្រោយឧត្តម។ ស.ជ.ប.ដ ជំរុញបណ្តាញដែលនាំទៅរកលទ្ធផលសិក្សាកាន់តែប្រសើរ ដោយជំរុញតំណភ្ជាប់អន្តរជាតិ និងពង្រឹងជំនាញសម្រាប់កិច្ចការស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកទេស។ ដើម្បីសម្រេចចក្ខុវិស័យរបស់សាកលវិទ្យាល័យ ស.ជ.ប.ដ បានពង្រឹងគុណភាពអប់រំតាមរយៈការពង្រឹង STEM និងកសិកម្ម ដើម្បីឱ្យការទទួលស្គាល់នៅកម្រិតជាតិ និងអន្តរជាតិ។ ពាក់ព័ន្ធនឹងការកសាង

សមត្ថភាពបុគ្គលិកវិញ បុគ្គលិកនិងសាស្ត្រាចារ្យរបស់ ស.ជ.ប.ជ បានទទួលការគាំទ្រពីមូលនិធិរដ្ឋាភិបាល ដូចជា ថវិកាកម្មវិធី (PB) និងគម្រោងកែលម្អឧត្តមសិក្សា (HEIP) ក៏ដូចជាកម្មវិធី Erasmus + និងគម្រោងផ្សេងៗផងដែរ។ ផែនការយុទ្ធសាស្ត្ររបស់ ស.ជ.ប.ជ ត្រូវបានបង្កើតឡើងតាមរយៈជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសពីរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានបង្កើតឡើងដោយប្រកាសអន្តរក្រសួងលេខ 3224 រយក្រប្រក ស្ដីពីការចេញផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ 2021-2030 របស់ ស.ជ.ប.ជ។ ស.ជ.ប.ជ មានចក្ខុវិស័យដើម្បីក្លាយខ្លួនគ្រឹះស្ថានឧត្តមសិក្សាស្រាវជ្រាវដែលមានកេរ្តិ៍ឈ្មោះល្បីគ្រប់ជ្រុងជ្រោយ ដោយមានកិត្យានុភាព ប្រណីតភាព និងទំនុកចិត្តក្នុងក្របខណ្ឌជាតិនិងអន្តរជាតិ។

*ប្រភេទនៃឧត្តមានុវត្តន៍៖ ការគ្រប់គ្រងហិរញ្ញវត្ថុដោយមានប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការលើកកម្ពស់ការជំរុញទឹកចិត្ត និងសកម្មភាពបំពេញការងារ*

## ៨.២. ព័ត៌មានលម្អិតអំពីឧត្តមានុវត្តន៍

ដូចសាកលវិទ្យាល័យរដ្ឋដទៃផ្សេងទៀតដែរ ស.ជ.ប.ជ ទទួលបានហិរញ្ញប្បទានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ស.ជ.ប.ជ គឺជាសាកលវិទ្យាល័យរដ្ឋពេញលេញមួយ ដែលមានការផ្ដល់ជូននូវសេវាសិក្សាធិការ និងស្រាវជ្រាវ។ ជាពិសេស បុគ្គលិកសិក្សាធិការ និងបុគ្គលិកគ្រប់គ្រង ក៏ដូចជាសាស្ត្រាចារ្យ គឺជាធនធានមនុស្សដ៏សំខាន់បំផុតក្នុងការដឹកនាំដំណើរការសកម្មភាពប្រតិបត្តិការរបស់គ្រឹះស្ថាននេះ។ ស.ជ.ប.ជ បានផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្តខ្លះដើម្បីលើកទឹកចិត្តបុគ្គលិកសម្រាប់គោលបំណងលើកកម្ពស់គុណភាពអប់រំ ផលិតភាព និងការបំពេញតាមតម្រូវការការងារ។ បន្ថែមលើនេះ សាស្ត្រាចារ្យ និងបុគ្គលិកត្រូវបានវាយតម្លៃដោយផ្អែកលើការបំពេញការងារក្នុងអំឡុងឆមាសនីមួយៗ។ យើងបានធ្វើរបាយការណ៍ស្វ័យវាយតម្លៃផ្ទៃក្នុង (SAR) ដើម្បីធ្វើការវាយតម្លៃពីខាងក្រៅលើអ្នកដែលទទួលបានការវាយតម្លៃពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក)។ ជាការសំខាន់ណាស់ដែលត្រូវប្រាកដថាកម្មវិធីសិក្សាទាំងអស់ស្របគ្នាជាមួយនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ (NQF) និងបទប្បញ្ញត្តិដទៃផ្សេងទៀត។ ពាក់ព័ន្ធនឹងឧត្តមានុវត្តន៍វិញ យើងបានប្រើឧបករណ៍ឌីជីថលដើម្បីគ្រប់គ្រងនិស្សិត បញ្ជីសារពើភ័ណ្ឌ និងការគ្រប់គ្រងហិរញ្ញវត្ថុ។ ស.ជ.ប.ជ បានរៀបចំជាស្រេចនូវរបាយការណ៍ហិរញ្ញវត្ថុរួមបញ្ចូលគ្នានៅក្នុងឆ្នាំ2020។ រាល់ព័ត៌មានហិរញ្ញវត្ថុទាំងអស់ ត្រូវបានកត់ត្រាទុក និងប្រមូលទុកនៅក្នុងប្រព័ន្ធនេះ។

## ៨.៣. តស្តុតាងនៃភាពជោគជ័យ (លទ្ធផលដែលសម្រេចបាន)

ផ្អែកលើបទពិសោធន៍ប្រាក់រង្វាន់លើកទឹកចិត្ត ការជំរុញលើកទឹកចិត្ត និងគណនេយ្យភាពក្នុងការកែលម្អសកម្មភាពបំពេញការងាររបស់បុគ្គលិក យើងត្រូវការមានសាមគ្គីភាព និងចែករំលែកអត្ថប្រយោជន៍រួមគ្នា សម្រាប់បុគ្គលិក និងបុគ្គលិកមហាវិទ្យាល័យទាំងអស់។

សាកលវិទ្យាល័យជាតិបាត់ដំបង មានបេសកកម្មធំៗចំនួនពីរ៖ (1) ដើម្បីបណ្តុះបណ្តាលនិស្សិតជាតិនិងអន្តរជាតិដែលមានសមត្ថភាព ដើម្បីបំពេញតាមតម្រូវការទីផ្សារការងារ និង (2) ដើម្បីធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រ ដើម្បីបង្កើនផលិតភាព និងកំណើនសេដ្ឋកិច្ចជាតិ។ ដើម្បីសម្រេចនូវបេសកកម្មនេះ ស.ជ.ប.ដ មានយុទ្ធសាស្ត្រសំខាន់ៗចំនួនបួន។ ទីមួយ ស.ជ.ប.ដ សហប្រតិបត្តិការដៃគូជាមួយសាកលវិទ្យាល័យជាតិនិងអន្តរជាតិ ក៏ដូចជាមួយគ្រឹះស្ថានដែលពាក់ព័ន្ធដទៃទៀត ដែលមានកម្មវិធីសិក្សាលក្ខណៈស្តង់ដា និងទទួលស្គាល់គុណភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ ទីពីរ ស.ជ.ប.ដ សហប្រតិបត្តិការជាមួយក្រុមហ៊ុនជាតិនិងអន្តរជាតិ និងសាកលវិទ្យាល័យនានាលើគម្រោងវិនិយោគស្រាវជ្រាវ។ ទីបី ស.ជ.ប.ដ រៀបចំវេទិកាប្រចាំឆ្នាំដើម្បីចែករំលែកពីលទ្ធផលសិក្សាស្រាវជ្រាវ ក៏ដូចជាផែនការកម្មវិធីវិនិយោគជាមួយនិស្សិត មាតាបិតា និងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ផងដែរ។ ស.ជ.ប.ដ ធ្វើទំនើបកម្មគ្រឹះស្ថានរបស់ខ្លួនតាមរយៈការបង្កើត ការចងក្រង និងការប្រើប្រាស់ទិន្នន័យ ដើម្បីស្វែងរកជំនួយពីក្រសួងពាក់ព័ន្ធ និងភាគីពាក់ព័ន្ធទាំងស់។ លទ្ធផលត្រូវផ្អែកលើការងារ ហើយប្រាក់រង្វាន់លើកទឹកចិត្តត្រូវផ្អែកលើសកម្មភាពបំពេញការងារ ដែលមានផលវិជ្ជមានច្រើននៅក្នុងបរិបទកម្ពុជា។ កស្តុតាងនៃផលវិជ្ជមាននេះ រួមបញ្ចូលទាំងការបង្កើនគុណភាពអប់រំ និងចំនួននៃការទទួលស្គាល់នៅកម្រិតមូលដ្ឋាន កម្រិតតំបន់ កម្រិតជាតិ និងកម្រិតអន្តរជាតិ។

### ៨.៤. សក្តានុពលសម្រាប់ការរៀនសូត្រ ឬការផ្ទេរបន្ត

ស.ជ.ប.ដ ត្រូវធ្វើការជំរុញការអនុវត្តការគ្រប់គ្រងធនធានមនុស្ស និងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីរក្សានូវធនធានមនុស្សរបស់ខ្លួន។ តាមរយៈជំនួយហិរញ្ញវត្ថុពីគម្រោងមួយចំនួន បុគ្គលិករបស់យើងមានឱកាសក្នុងការបង្កើនគុណវុឌ្ឍិ និងអភិវឌ្ឍសមត្ថភាពរបស់ពួកគេ តាមរយៈការបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ក៏ដូចជាបានចូលរួមក្នុងការបណ្តុះបណ្តាល និងសិក្ខាសាលាមួយចំនួនផងដែរ។ ស.ជ.ប.ដ មានផែនការសម្របសម្រួលដល់ការចាត់តាំងបុគ្គលិកមហាវិទ្យាល័យ ដើម្បីទទួលបានគោរមងារដូចជា ជំនួយការសាស្ត្រាចារ្យ សាស្ត្រាចារ្យរង ក៏ដូចជាផ្តល់ប្រាក់បៀវត្សរ៍បន្ថែម និងរង្វាន់ដទៃផ្សេងទៀតជូនដល់បុគ្គលិកដែលរួមចំណែកដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់សាកលវិទ្យាល័យផងដែរ។

### ៨.៥. ព័ត៌មានបន្ថែម

ស.ជ.ប.ដ មានការរីកច្រើនយ៉ាងច្រើននៅក្នុងគម្រោងជាតិនិងអន្តរជាតិជាច្រើន ដើម្បីលើកកម្ពស់ការរៀន និងការបង្រៀន ក៏ដូចជាការបង្កើនសមត្ថភាពស្ថាប័នរបស់សាកលវិទ្យាល័យផងដែរ ដូចជា តាមរយៈកម្មវិធី Erasmus+, HEIP (ធនាគារពិភពលោក), JICA, KOICA, TICA, GIZ, AUSIAD, USAID, វិទ្យាស្ថានខុងជឺ ។ល។

## ៨.៦. ព័ត៌មានលម្អិតទំនាក់ទំនង

**សាកលវិទ្យាល័យជាតិបាត់ដំបង**

អាសយដ្ឋាន៖  ផ្លូវជាតិលេខ5 សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង ប្រទេសកម្ពុជា

**អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ, ស.ជ.ប.ដ, គម្រោង BALANCE**

បណ្ឌិត សំ រានី សាកលវិទ្យាធិការរង

ទូរសព្ទ៖ (+855) 12 64 66 85

អ៊ីម៉ែល៖ sam.rany@nubb.edu.kh

គេហទំព័រ៖ www.nubb.edu.kh

# សាកលវិទ្យាល័យស្វាយរៀង

# ៩
# សាកលវិទ្យាល័យស្វាយរៀង

## ប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការជំរុញការលើកទឹកចិត្ត និងការងារបំពេញការងារ៖ មេរៀនពីសាកលវិទ្យាល័យស្វាយរៀង (ស.ស.រ)

### ៩.១. សាវតារ

សាកលវិទ្យាល័យស្វាយរៀងមានទីតាំងនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា មានចម្ងាយ 125 គម ពីរាជធានីភ្នំពេញ។ សាកលវិទ្យាល័យនេះគឺជាសាកលវិទ្យាល័យរដ្ឋតែមួយគត់នៃខេត្តស្វាយរៀង ដែលស្ថិតនៅជិតនឹងតំបន់មានសក្តានុពលបំផុតសម្រាប់ការអភិវឌ្ឍធុរកិច្ចនៅក្នុងវិស័យឯកជន ទាំងនៅកម្រិតជាតិ និងកម្រិតអន្តរជាតិ។ ស.ស.រ គឺជាគ្រឹះស្ថានសិក្សាមួយដែលគាំទ្រដល់ការបង្កើតធនធានមនុស្ស ដើម្បីបំពេញតាមតម្រូវការខ្ពស់ផ្នែកទីផ្សារការងារនៅក្នុងវិស័យឧស្សាហកម្ម ជាពិសេសសម្រាប់តំបន់សេដ្ឋកិច្ចពិសេស (SEZ)។ សាកលវិទ្យាល័យបានបង្កើតមហាវិទ្យាល័យចំនួនប្រាំ រួមមាន មហាវិទ្យាល័យកសិកម្ម មហាវិទ្យាល័យគ្រប់គ្រងធុរកិច្ច មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស និងមហាវិទ្យាល័យសង្គមសាស្ត្រ។ សាកលវិទ្យាល័យទើបនឹងបើកដំណើរការកម្មវិធីថ្មីសម្រាប់ដេប៉ាតឺម៉ង់វិស្វកម្មថ្មីនៅក្នុង មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នោះគឺដេប៉ាតឺម៉ង់ វិស្វកម្មមេកានិច (ME)។ ពាក់ព័ន្ធនឹងការកសាងសមត្ថភាពបុគ្គលិកវិញ បុគ្គលិកនិងសាស្ត្រាចារ្យរបស់ ស.ស.រ បានទទួលការគាំទ្រពីមូលនិធិពីរដ្ឋាភិបាល ដូចជា ថវិកាកម្មវិធី (PB) និងគម្រោងកែលម្អឧត្តមសិក្សា (HEIP) ក៏ដូចជាកម្មវិធី Erasmus + និងគម្រោងផ្សេងៗផងដែរ។

**ប្រភេទនៃឧត្តមានុវត្តន៍៖** ***ការគ្រប់គ្រងហិរញ្ញវត្ថុដោយមានប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការលើកកម្ពស់ការជំរុញទឹកចិត្ត និងសកម្មភាពបំពេញការងារ***

### ៩.២. ព័ត៌មានលម្អិតអំពីឧត្តមានុវត្តន៍

ក្នុងនាមជាគ្រឹះស្ថានឧត្តមសិក្សារដ្ឋនៅក្នុងប្រទេសកម្ពុជា ដោយទទួលបានហិរញ្ញប្បទានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស.ស.រ គឺជាគ្រឹះស្ថានមួយដែលមានផ្តល់ជូននូវសេវាសិក្សាធិការនិងស្រាវជ្រាវ។ ក្នុងស្មារតីនេះ បុគ្គលិកសិក្សាធិការ និងបុគ្គលិកគ្រប់គ្រងដ៏ដូចជាសាស្ត្រាចារ្យ គឺជាធនធានមនុស្សដ៏សំខាន់ក្នុងការដឹកនាំដំណើរការសកម្មភាពប្រតិបត្តិការរបស់គ្រឹះស្ថាន

នេះ។ ដើម្បីធានាថា គណៈគ្រប់គ្រងរបស់ ស.ស.រ បានអនុម័តលើនីតិវិធីហិរញ្ញវត្ថុផ្ទៃក្នុងសម្រាប់ថ្លៃសិក្សា ដើម្បីប្រើប្រាស់ប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ជម្រុញលើកទឹកចិត្ត និងផលិតភាពនៅក្នុងគ្រឹះស្ថាន។ ពាក់ព័ន្ធនឹងចំណុចនេះ បុគ្គលិកគ្រប់គ្រងរបស់ ស.ស.រ អាចទទួលបានប្រាក់បៀវត្សរ៍ពីរដ្ឋាភិបាលផងនិងពីប្រាក់ឈ្នួលប្រចាំខែពីសាកលវិទ្យាល័យផង។ មន្ត្រីរាជការបម្រើការជាបុគ្គលិកសិក្សា (សាស្ត្រាចារ្យ) ទទួលបានប្រាក់បៀវត្សរ៍ពីរដ្ឋាភិបាលផង និងពីប្រាក់ឈ្នួលបង្រៀនផង។ នីតិវិធីនេះអាចលើកទឹកចិត្តដល់បុគ្គលិក និងសាស្ត្រាចារ្យជាច្រើនរបស់យើង ឱ្យបំពេញការងាររបស់ពួកគេដោយការពេញចិត្តដោយសារការធ្វើបែបនេះ អាចជួយបង្កើនប្រាក់ចំណូលបានមួយចំណែកទៀត។

## ៩.៣. ឥទ្ធិពលនៃភាពជោគជ័យ (លទ្ធផលដែលសម្រេចបាន)

តាមរយៈការអនុវត្ត ប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការជំរុញការលើកទឹកចិត្ត និងការងារបំពេញការងារ ឃើញថាមានលទ្ធផលល្អមួយចំនួននៅក្នុងការបង្រៀន និងបុគ្គលិករបស់យើង។ បុគ្គលិកចាស់មួយចំនួនសុខចិត្តចែករំលែកបទពិសោធបង្រៀនផ្ទាល់ខ្លួនដល់បុគ្គលិកថ្មីនៅក្នុងមហាវិទ្យាល័យ ហើយព្រឹទ្ធបុរស និងបុគ្គលិកមហាវិទ្យាល័យ ទទួលបានការលើកទឹកចិត្តឱ្យធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សារបស់ពួកគេ ដើម្បីបំពេញតាមតម្រូវការទីផ្សារការងារ។

**យើងតាមនីតិវិធីហិរញ្ញវត្ថុរបស់ ស.ស.រ ដែលបានអនុម័តនៅក្នុងឆ្នាំ2006 បុគ្គលិកបង្រៀនរបស់យើង ទទួលបានការលើកទឹកចិត្ត ដោយសារប្រាក់ឈ្នួលថ្លៃបង្រៀន បន្ថែមពីលើប្រាក់បៀវត្សរ៍ដែលទទួលបានពីរដ្ឋាភិបាល។ ក្នុងន័យនេះ បុគ្គលិកបង្រៀនរបស់ ស.ស.រ អាចទទួលបានប្រាក់បៀវត្សរ៍របស់ខ្លួនផង និងប្រាក់ថ្លៃឈ្នួលបង្រៀនផង។**

## ៩.៤. សក្តានុពលសម្រាប់ការរៀនសូត្រ ឬការផ្ទេរបន្ត

តាមរយៈការគ្រប់គ្រងបានល្អ និងការគាំទ្រពីគម្រោងជាក់លាក់មួយចំនួន បុគ្គលិករបស់យើងខ្លះ ទទួលបានឱកាសល្អក្នុងការបង្កើនគុណវុឌ្ឍិ និងអភិវឌ្ឍសមត្ថភាពរបស់ពួកគេតាមរយៈការបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ក៏ដូចជាបានចូលរួមក្នុងការបណ្តុះបណ្តាល និងសិក្ខាសាលាមួយចំនួនផងដែរ។

## ៩.៥. ព័ត៌មានបន្ថែម

សូមអានឯកសារភ្ជាប់អំពីនីតិវិធីហិរញ្ញវត្ថុរបស់ ស.ស.រ ជាភាសាខ្មែរ។

## ៩.៦. ព័ត៌មានលម្អិតទំនាក់ទំនង

**សាកលវិទ្យាល័យស្វាយរៀង**
អាសយដ្ឋាន៖ ភូមិចំបក់ សង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង ប្រទេសកម្ពុជា
**អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ, ស.ស.រ, គម្រោង BALANCE**
លោក ស៊ិន ពុទ្ធាសាធ សាកលវិទ្យាធិការរង
ទូរសព្ទ៖ (+855) 12 75 67 87
អ៊ីម៉ែល៖ spsath@sru.edu.kh
គេហទំព័រ៖ www.sru.edu.kh

# សាកលវិទ្យាល័យភូមិន្ទកសិកម្ម

# ១០
# សាកលវិទ្យាល័យភូមិន្ទកសិកម្ម
## ការអនុវត្តការគ្រប់គ្រងថវិកាផ្ទៃក្នុង សម្រាប់ផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់បុគ្គលិកបង្រៀន

### ១០.១. សាវតារ

សាកលវិទ្យាល័យភូមិន្ទកសិកម្ម (ស.វ.ភ.ក) គឺជាគ្រឹះស្ថានឧត្តមសិក្សារដ្ឋឈានមុខគេមួយនៅក្នុងប្រទេសកម្ពុជា និងជាគ្រឹះស្ថានសំខាន់ជាងគេមួយដែលទទួលបានការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទនៃរាជរដ្ឋាភិបាលកម្ពុជា។ ស.វ.ភ.ក ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ1964។ នៅក្នុងឆ្នាំសិក្សា 2018-2019 ចំនួននិស្សិតដែលបានសិក្សាថ្នាក់បរិញ្ញាបត្ររង (137 នាក់) ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ (2806 នាក់) ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ (44 នាក់) និងថ្នាក់បណ្ឌិត (47 នាក់) ដែលសរុបទាំងអស់មានចំនួន 3034 នាក់ (ក្នុងចំណោមនោះ មាន 1062 នាក់ជានិស្សិតស្រី) សាកលវិទ្យាល័យមានមហាវិទ្យាល័យចំនួន 10 មជ្ឈមណ្ឌលស្រាវជ្រាវចំនួន 9 ការិយាល័យចំនួន 4 អង្គភាពចំនួន 3 និងថ្នាក់បរិញ្ញាបត្រចំនួនមួយ ដែលមានបុគ្គលិក និងសាស្ត្រាចារ្យចំនួន 153 រូប។ សាកលវិទ្យាល័យមានបុគ្គលិកបង្រៀនចំនួន 305 រូប ទាំងបុគ្គលិកជាតិ (162 នាក់) និងបុគ្គលិកអន្តរជាតិ (143 នាក់)។ សាកលវិទ្យានេះដើរតួនាទីយ៉ាងសំខាន់ក្នុងកម្មវិធីអប់រំដែលពាក់ព័ន្ធវិស័យកសិកម្ម និងវិស័យដែលពាក់ព័ន្ធ សម្រាប់គ្រប់កម្រិតសិក្សា ដោយផ្តោតលើការអប់រំ ការស្រាវជ្រាវ និងការពង្រីកបន្ថែមជាពិសេសការកសាងសមត្ថភាព និងការស្រាវជ្រាវពាក់ព័ន្ធនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ចក្ខុវិស័យនេះ គឺដើម្បីក្លាយខ្លួនជាសាកលវិទ្យាល័យកសិកម្មដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា ដោយទទួលស្គាល់នូវភាពល្អប្រសើរកម្រិតពិភពលោកនៅក្នុងការអប់រំ ការស្រាវជ្រាវ និងការពង្រីកបន្ថែម។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ បេសសកម្មត្រូវផ្តល់នូវឱកាសអប់រំល្អប្រសើរ និងពាក់ព័ន្ធនៅក្នុងផ្នែកកសិកម្ម និងវិស័យដែលពាក់ព័ន្ធ តាមរយៈកម្មវិធីបង្រៀន ស្រាវជ្រាវ និងពង្រីកបន្ថែមដែលមានគុណភាព ដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ជាតិនិងសកលលោក ដើម្បីផលិតនូវបុគ្គលដែលមានការប្រកួតប្រជែងកម្រិតពិភពលោក គាំទ្រដល់ការអភិវឌ្ឍ

សេដ្ឋកិច្ច និងជំរុញចីរភាពបរិស្ថាន។ បន្ថែមលើនេះ សាកលវិទ្យាល័យក៏បានជំរុញវប្បធម៌ស្រាវជ្រាវតាមរយៈការចូលរួមក្នុងសិក្ខាសាលា និងការបណ្តុះបណ្តាលទាំងក្នុងស្រុក និងអន្តរជាតិ ដើម្បីឱនិស្សិតមានឱកាសពង្រឹងចំណេះដឹងរបស់ពួកគេនៅក្នុងមជ្ឈដ្ឋានខុសៗគ្នា។

## ១០.២. ព័ត៌មានលម្អិតអំពីឧត្តមានុវត្តន៍

មានប្រព័ន្ធគណនេយ្យភាពមួយសម្រាប់ដំណើរការ និងការព្រួតពិនិត្យប្រតិបត្តិការសាច់ប្រាក់ធុរកិច្ច។ ប្រទេសកម្ពុជាបានអនុវត្តប្រព័ន្ធគណនេយ្យយ៉ាងពេញលេញ ដែលបានអនុម័តយកមកប្រើនូវគំរូ IFRS រួមបញ្ចូលទាំងការបកស្រាយ ដែលបានបោះពុម្ពផ្សាយដោយក្រុមប្រឹក្សាភិបាលស្តង់ដាគណនេយ្យអន្តរជាតិ (IASB)។ បណ្តុះស្តង់ដាពេញលេញ រួមទាំងការបកស្រាយផង ត្រូវបានហៅថា ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRS”)។

កំណែទម្រង់រដ្ឋបាលសាធារណៈ គឺជាគោលនយោបាយឈ្នះ ឈ្នះរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយសារគោលនយោបាយនេះហើយ ទើបនាំឱ្យមានស្ថេរភាពពេញលេញនៅក្នុងប្រទេស។ មានការធ្វើកំណែទម្រង់ជាច្រើន រួមបញ្ចូលទាំងការអភិវឌ្ឍមូលដ្ឋានទិន្នន័យសម្រាប់មន្ត្រីរាជការ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាពត៌មានដើម្បីគ្រប់គ្រងធនធានមនុស្ស ប្រាក់បៀ-វត្សរ៍ និងប្រាក់ដំណាច់ ការរៀបចំការច្របាច់បញ្ចូលគ្នានូវប្រព័ន្ធធ្វើចំណាត់ថ្នាក់ការជ្រើសរើសបុគ្គលិកថ្មី ឬការចូលនិវត្តន៍ ក្នុងកំណែទម្រង់ផ្សេងៗទៀត។ រដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងពាក់ព័ន្ធនឹងកំណែទម្រង់រដ្ឋបាលសាធារណៈ ក្នុងនាមជាផ្នែកអាទិភាពមួយរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាពការងារ ក៏ដូចជាសមត្ថភាពរដ្ឋបាលសាធារណៈនៅក្នុងប្រទេសផងដែរ។ គ្រឹះស្ថានឧត្តមសិក្សារដ្ឋ (HEI) បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាអប់រំ ដែលធនធានមនុស្សបានក្លាយជាអ្នកកាច់ចង្កូតដ៏សំខាន់នៃការអភិវឌ្ឍប្រទេសនៅក្នុងផ្នែកទាំងអស់។ ជំនាញគ្រប់គ្រង មានតម្រូវការជាចាំបាច់ជាកត្តាគន្លឹះនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។ ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព ត្រូវការឱ្យអ្នកគ្រប់គ្រងមានទំនួលខុសត្រូវលើសកម្មភាព និងសមិទ្ធផលនានាដើម្បីបានត្រឡប់មកវិញនូវសកម្មភាពគ្រប់គ្រងដែលល្អបំផុតពីធាតុចូលរបស់ពួកគេ។ នៅកម្រិតគណៈគ្រប់គ្រងរបស់ ស.វ.ភ.ក អ្នកគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវលើការបំពេញការងាររបស់ខ្លួន។ គប្បីត្រូវពន្យល់ថា ការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងវិស័យរដ្ឋ គឺមានគោលដៅក្នុងការធានានូវប្រសិទ្ធភាព និងប្រសិទ្ធផលសេដ្ឋកិច្ច ក្នុងការពង្រឹងធាតុចូល ដើម្បីសម្រេចបានលទ្ធផលដែលចង់បាន ដែលនឹងបំពេញតម្រូវការរបស់សាកលវិទ្យាល័យទាំងមូល។

ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងត្រូវបានកំណត់ដើម្បីធានាថា គោលនយោបាយ និងនីតិវិធីដែលបានដាក់ឱ្យដំណើរការនោះ ការពារដល់ទ្រព្យសកម្មរបស់ស្ថាប័ន និងមានការទទួលខុសត្រូវការធ្វើរបាយការណ៍ហិរញ្ញវត្ថុ។ ថវិកាផ្ទៃក្នុងសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់បុគ្គលិក

បង្រៀនរបស់សាកលវិទ្យាល័យ គឺធ្វើឡើងដើម្បីធានានូវសកម្មភាពប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាព ភាពអាចជឿទុកចិត្តបាននៃព័ត៌មាន អនុលោមភាពតាមច្បាប់ជាធរមាន និងតារាងពេលវេលាសម្រាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុ។

បុគ្គលិកសិក្សាធិការ បុគ្គលិកគ្រប់គ្រង និងសាស្ត្រាចារ្យ គឺជាតួអង្គសំខាន់នៅក្នុងសកម្មភាពប្រតិបត្តិការរបស់ស្ថាប័ន។ ការគ្រប់គ្រងនិងការអនុវត្តជាផ្លូវការនូវឧត្តមានុវត្តន៍នៃការគ្រប់ថវិកាផ្ទៃក្នុងនេះ រួមជាមួយសូចនាករវាស់ស្ទង់សមស្របអាចបង្កើនគុណភាពរបស់គ្រឹះស្ថានឧត្តមសិក្សា។ បន្ថែមលើនេះ របាយការណ៍ហិរញ្ញវត្ថុជួយអ្នកគ្រប់គ្រងធ្វើការពិភាក្សាលទ្ធផល និងការចំណាយ ក៏ដូចជាការបំពេញការងារទៅតាមថវិកា ហើយតាមពិត អាចមានប្រសិទ្ធភាពប្រសិនបើពិចារណាលើរបាយការណ៍គ្រប់គ្រងហិរញ្ញវត្ថុ ដែលបានរៀបចំដោយការិយាល័យ គណនេយ្យករ ដោយប្រើប្រព័ន្ធព័ត៌មានគណនេយ្យ។ ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុង រួមបញ្ចូលធាតុសំខាន់ចំនួនបួន៖ ការកំណត់កម្មវត្ថុ ឬគោលដៅសម្រាប់សកម្មភាពបង្រៀន ការវាស់ស្ទង់សកម្មភាពជាក់ស្តែង ការប្រៀបធៀបជាមួយនឹងស្តង់ដាផែនការសិក្សាធិការ និងការចាត់វិធានការដើម្បីកែលម្អចំណុចខ្វះខាតនានា។ ហេតុនេះ ការគ្រប់គ្រងគឺជាដំណើរការនៃសកម្មភាពគ្រប់គ្រងតាមដាន ដើម្បីធានាថា លទ្ធផលនោះស្របទៅតាមផែនការ។ ការគ្រប់គ្រងហិរញ្ញវត្ថុ គឺត្រូវបានបង្ហាញនៅក្នុងការផ្តល់សិទ្ធិទូទៅ ភារកិច្ច ការរក្សាកំណត់ត្រា ការការពារ និងការផ្ទៀងផ្ទាត់។ ដើម្បីជៀសវាងកំហុសនៅក្នុងផ្នែកហិរញ្ញវត្ថុសិក្សាធិការ កម្រិតថ្នាក់ដឹកនាំត្រូវមាននីតិវិធីនិងទំនួលខុសត្រូវច្បាស់លាស់។ បន្ថែមលើនេះ សវនកម្មផ្ទៃក្នុងសមស្រប ត្រូវធ្វើឡើងឱ្យបានគ្រប់គ្រាន់នៅ HEI ហើយសវនកម្មរបស់រដ្ឋាភិបាល ត្រូវធ្វើឡើងជាប្រចាំ។ ហេតុនេះហើយ ការគ្រប់គ្រងថវិកាផ្ទៃក្នុង គប្បីអនុវត្តឱ្យបានសមស្រប។ ចុងក្រោយ បុគ្គលិកបង្រៀនបានទទួលស្គាល់នូវសារៈសំខាន់នៃការចូលរួមចំណែកជាវិជ្ជមានដល់សកម្មភាពការងាររបស់សាកលវិទ្យាល័យ ថាជាឧត្តមានុវត្តន៍មួយសម្រាប់ HEI ហើយដោយសារចំណុចនេះហើយ ការវាយតម្លៃសកម្មភាពការងាររបស់សាស្ត្រាចារ្យ រួមចំណែកដល់សក្ខីភាពនៃក្របខណ្ឌគុណភាពជាតិ និងផែនការយុទ្ធសាស្ត្រអប់រំរបស់ ស.វ.ភ.ក។

## ១០.៣. តស្ចុតាងនៃភាពជោគជ័យ (លទ្ធផលដែលសម្រេចបាន)

សូចនាករមួយចំនួនត្រូវបានបង្កើតឡើង ដើម្បីសម្រេចនូវគុណភាពនៃការអប់រំតាមរយៈការអនុវត្តផ្ទៃក្នុងនូវការគ្រប់គ្រងថវិកាសម្រាប់ផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់បុគ្គលិកបង្រៀន ដែលរួមបញ្ចូលទាំងការអនុវត្តប្រកបដោយវិន័យ និងសមិទ្ធផលនៃសកម្មភាពបង្រៀន ដែលបានវាយតម្លៃជារៀងរាល់ខែ។ ក៏រួមបញ្ចូលទាំងផែនការបង្រៀន (កម្មវត្ថុសិក្សានៃកម្មវិធីកម្មវត្ថុសិក្សានៃវគ្គសិក្សា កម្មវត្ថុសិក្សារបស់មេរៀន វិធីសាស្ត្របង្រៀន សកម្មភាពវាយតម្លៃម៉ោងបង្រៀន និងបញ្ជីវត្តមាននិស្សិត) ដោយបញ្ជាក់ពីសកម្មភាពបំពេញការងារ ដំណើរការការងារ និងគុណភាព។ បុគ្គលិកទាំងអស់ អនុវត្តទៅតាមវិធានផ្ទៃក្នុង និងបទប្បញ្ញត្តិនានា

បំណែងកិច្ចការស្របទៅតាមស្តង់ដា សង្គតិភាព និងតារាកាលវិភាគ ដោយផ្តល់សេវាកម្មល្អបំផុតដល់និស្សិត ដើម្បីទទួលបានប្រយោជន៍ពិស្តង់ដាអប់រំជាតិ។

បុគ្គលិកអប់រំ ត្រូវបានវាយតម្លៃមួយខែម្តង ចំណែកឯសកម្មភាពការងាររបស់សាស្ត្រាចារ្យត្រូវបានវាយតម្លៃទៅតាមលក្ខខណ្ឌវិនិច្ឆ័យរៀបរាប់នៅខាងលើ ទៅតាមឆមាស។ ការវាយតម្លៃលើសកម្មភាពការងាររបស់សាស្ត្រាចារ្យអនុវត្តតាមក្របខណ្ឌគុណវុឌ្ឍិជាតិ (NQF) និងផែនការយុទ្ធសាស្ត្រសិក្សាធិការរបស់ ស.វ.ភ.ក។ ហេតុនេះហើយ ភស្តុតាងនៃផលឥទ្ធិពលពីសកម្មភាពផ្ទៃក្នុងនៃការគ្រប់គ្រងថវិកានេះ បង្កើតមុខមាត់វិជ្ជមានដល់សកម្មភាពការងាររបស់សាកលវិទ្យាល័យ។

## ១០.៤. សក្ដានុពលសម្រាប់ការរៀនសូត្រ ឬការផ្ទេរបន្ត

ដោយសារការឆ្លងរាលដាលនៃជំងឺកូវីដ-19 ការអនុវត្តសកម្មភាពផ្ទៃក្នុងនៃការគ្រប់គ្រងថវិកាសម្រាប់ផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់បុគ្គលិកបង្រៀន ត្រូវជួបការលំបាក មិនដូចជាការអនុវត្តជាក់ស្តែងទេ។ ក៏ប៉ុន្តែ ប្រព័ន្ធនេះត្រូវបានអនុវត្តនៅគ្រប់សាកលវិទ្យាល័យទាំងអស់។ និយោជិត ទាំងបុគ្គលិកសិក្សា និងសាស្ត្រាចារ្យនៅក្រោមក្របខណ្ឌសាកលវិទ្យាល័យ អនុវត្តការបំពេញការងារតាមអនឡាញជាចម្បង ផ្អែកលើសូចនាករដែលបានកំណត់ជាមុន ដែលបានបង្កើតឡើងនៅក្នុងប្រព័ន្ធថវិកាផ្ទៃក្នុង។

## ១០.៥. ព័ត៌មានបន្ថែម

សាកលវិទ្យាល័យកំពុងអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ2021-2030។

## ១០.៦. ព័ត៌មានលម្អិតទំនាក់ទំនង

**សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

អាសយដ្ឋាន៖ ប្រអប់សំបុត្រ 2696 ចំការដូង ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

**មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ, គម្រោង BALANCE, ស.វ.ភ.ក**

លោក គឹម សុបិន្ត ព្រឹទ្ធបុរសនៃមហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ ទូរសព្ទ ៖

(+855) 12 724 686

អ៊ីម៉ែល៖ kimsoben@gmail.com

គេហទំព័រ៖ www.rua.edu.kh

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# ១១

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## អភិបាលកិច្ច និងគណនេយ្យភាព៖ ករណី ស.ភ.ភ.ព

### ១១.១. សាវតារ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ហៅកាត់ថា "ស.ភ.ភ.ព") ត្រូវបានសាងសង់ឡើងនៅទសវត្សរ៍ឆ្នាំ1960។ សាកលវិទ្យាល័យនេះ ជាសាកលវិទ្យាល័យធំជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា។ ស.ភ.ភ.ព មានបុគ្គលិករដ្ឋបាលចំនួន 76 រូប និងបុគ្គលិកសិក្សាចំនួន 307 រូប។ ស.ភ.ភ.ព ផ្តោតសំខាន់លើចំណុចដូចខាងក្រោម៖

1. ការកសាងសមត្ថភាព (ចំណេះដឹង ជំនាញ គុណតម្លៃ និងអត្តចរិត) សម្រាប់និស្សិតនៅគ្រប់កម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាលទាំងអស់ ហើយបំពាក់បំប៉ននិស្សិតនូវជំនាញសហគ្រិនភាព ជំនាញនវានុវត្តន៍ សមត្ថភាពចម្រុះវប្បធម៌ និងជំនាញស្វែងរកការងារ។
2. ជំរុញលើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍនៅគ្រប់កម្មវិធីសិក្សាថ្នាក់បរិញ្ញបត្រ។
3. ក្លាយជាគ្រឹះស្ថានឈានមុខគេនៅក្នុងផ្នែកវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ និង STEM (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា)។

ស.ភ.ភ.ព មានមហាវិទ្យាល័យចំនួន 5 វិទ្យាស្ថានចំនួន 1 និងមជ្ឈមណ្ឌលស្រាវជ្រាវចំនួន 1 ដូចខាងក្រោម៖

1. មហាវិទ្យាល័យវិទ្យាសាស្ត្រ
2. មហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ
3. មហាវិទ្យាល័យវិស្វកម្ម
4. មហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍
5. មហាវិទ្យាល័យអប់រំ
6. វិទ្យាស្ថានភាសាបរទេស
7. មជ្ឈមណ្ឌលស្រាវជ្រាវសូត្រ

បច្ចុប្បន្ន ស.ភ.ភ.ព បាននិងកំពុងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ។ ស.ភ.ភ.ព បានជួលក្រុមហ៊ុនឯកជនឱ្យបង្កើតសូហ្វវែរគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុរបស់សាកល

វិទ្យាល័យ។ លទ្ធផលដែលបានពីប្រព័ន្ធគ្រប់គ្រងថ្មីនេះ នឹងផ្តល់ចម្លើយថ្មីៗសម្រាប់សំណួរដែលចោទសួរដោយបុគ្គលិកថ្នាក់គ្រប់គ្រង និងម្ចាស់ជំនួយ។

*ប្រភេទនៃឧត្តមានុវត្តន៍៖* តួនាទី ទំនួលខុសត្រូវ ប្រតិភូកម្ម និងរចនាសម្ព័ន្ធនៃការធ្វើសេចក្តីសម្រេចចិត្ត គ្រោងប្រាក់រង្វាន់លើកទឹកចិត្ត

## ១១.២. ព័ត៌មានលម្អិតអំពីឧត្តមានុវត្តន៍

គ្រឹះស្ថានឧត្តមសិក្សាមួយ គឺស្ថាប័នផ្តល់សេវាកម្ម ដែលទទួលបានមូលនិធិពីរដ្ឋាភិបាល និងម្ចាស់ជំនួយ និងថ្លៃសិក្សាពីនិស្សិត។ ការគ្រប់គ្រងមូលនិធិទាំងនេះ គាំទ្រដល់សកម្មភាពរបស់សកលវិទ្យាល័យក្នុងកិច្ចការសំខាន់ៗសម្រាប់អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ។

- គ្រប់ដេប៉ាតឺម៉ង់ និងការិយាល័យទាំងអស់ អាចស្នើសុំការទូទាត់ផ្អែកតាមថវិកាដែលបានអនុម័តរួចរបស់ខ្លួន។
- សំណើត្រូវធ្វើការត្រួតពិនិត្យដោយព្រឹទ្ធបុរសរបស់មហាវិទ្យាល័យ ឬប្រធានការិយាល័យ ត្រួតពិនិត្យដោយប្រធានការិយាល័យគណនេយ្យ ហើយបន្ទាប់មក ត្រូវអនុម័តដោយសាកលវិទ្យាធិការ ឬសាកលវិទ្យាធិការរងទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ។ សាកលវិទ្យាធិការរងទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ អាចអនុម័តការទូទាត់ប្រាក់រហូតដល់ 2,000 ដុល្លារអាមេរិក។
- ផ្អែកតាមសំណើដែលអនុម័តរួច គណនេយ្យករអាចរៀបចំសក្ខីបត្រទូទាត់ប្រាក់ ដែលមានការត្រួតពិនិត្យដោយប្រធានការិយាល័យគណនេយ្យ និងអនុម័តដោយសាកលវិទ្យាធិការ ឬសាកលវិទ្យាធិការរងទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ។
- ការទូទាត់ប្រាក់រហូតដល់ 500 ដុល្លារអាមេរិក អាចធ្វើឡើងបានតាមរយៈប្រាក់រដ្ឋទេយ្យ។ ចំពោះការទូទាត់លើសពី 500 ដុល្លារអាមេរិក ត្រូវធ្វើការទូទាត់តាមមូលប្បទានបត្រ។ ដើម្បីសម្របសម្រួលដល់ការទូទាត់ប្រាក់ យើងមានគោលនយោបាយផ្ទៃក្នុង ដែលតាមរយៈនេះ មានប្រាក់ចំនួន 10,000 ដុល្លារអាមេរិក ត្រូវបានរក្សាទុកនៅក្នុងឃ្លាំងប្រាក់រដ្ឋទេយ្យរបស់យើង។
- ស.ភ.ភ.ព ប្រើមូលដ្ឋានសាច់ប្រាក់គណនេយ្យដែលបានកែប្រែ (សម្រាប់ប្រាក់បុរេប្រទាន) សម្រាប់ឆ្នាំសារពើពន្ធគណនេយ្យផង និងឆ្នាំសិក្សាផង ពាក់ព័ន្ធនឹងថវិកានិងរបាយការណ៍។
- ថ្លៃសិក្សាត្រូវបានប្រើជាប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់បុគ្គលិកទាំងអស់។ បុគ្គលិកគ្រប់គ្រងរបស់ ស.ភ.ភ.ព អាចទទួលបានប្រាក់បៀវត្សរ៍ពីរដ្ឋាភិបាលផងនិងពីប្រាក់ឧបត្ថម្ភប្រចាំខែពីសាកលវិទ្យាល័យផង។ មន្ត្រីរាជការដែលបម្រើការជាបុគ្គលិក ប្រាក់បៀវត្សរ៍ទាំងពីរនេះត្រូវបានផ្តល់ដោយរដ្ឋាភិបាល ចំណែកឯប្រាក់ថ្លៃឈ្នួលបង្រៀន ត្រូវផ្តល់ដោយសាកលវិទ្យាល័យ។

## ១១.៣. ឥស្សរភាពនៃភាពជោគជ័យ (លទ្ធផលដែលសម្រេចបាន)

ស.ភ.ភ.ព អាចគ្រប់គ្រងបង្កាន់ដៃទទួលប្រាក់ និងការទូទាត់ប្រាក់បានយ៉ាងរលូត ពីមូលនិធិគ្រប់ប្រភព និងអាចធ្វើរបាយការណ៍សម្រាប់អ្នកប្រើប្រាស់បានទាន់ពេលវេលា។

បច្ចុប្បន្ននេះ និស្សិតអាចធ្វើការបង់ប្រាក់ទៅសាកលវិទ្យាល័យតាមរយៈប្រព័ន្ធធនាគារដែលបានកំណត់។ នេះមិនមែនគ្រាន់តែកាត់បន្ថយការជួបមុខគ្នាផ្ទាល់នៅសាកលវិទ្យាល័យក្នុងអំឡុងពេលជំងឺកូវីដ-19 ប៉ុណ្ណោះទេ តែវាក៏បានបង្ហាញពីភាពចាស់ទុំក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៅសាកលវិទ្យាល័យផងដែរ។

ដោយមានគ្រោងការប្រាក់រង្វាន់លើកទឹកចិត្តសមស្រប យើងមានក្របខណ្ឌការងារដែលល្អទាំងបុគ្គលិករដ្ឋបាល និងបុគ្គលិកសិក្សា។

## ១១.៤. សក្ដានុពលសម្រាប់ការរៀនសូត្រ ឬការផ្ទេរបន្ត

បុគ្គលិកគ្រប់គ្រងហិរញ្ញវត្ថុ ទទួលបានការបណ្តុះបណ្តាលនៅលើការងារផ្ទាល់ តាមរយៈរដ្ឋាភិបាល និងគម្រោងជាក់លាក់មួយចំនួន។ ក្រៅពីនេះ ពួកគាត់ក៏មានឱកាសល្អក្នុងការបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឬថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យផងដែរ។

## ១១.៥. ព័ត៌មានលម្អិតទំនាក់ទំនង

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

អាសយដ្ឋាន៖ មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរសព្ទ៖ (+855) 23 883 640

**អង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ, ស.ភ.ភ.ព, គម្រោង BALANCE**

លោក ពន់ ឆាយ សាកលវិទ្យាធិការរង

ទូរសព្ទ៖ (+855) 16 857171

គេហទំព័រ៖ www.rupp.edu.kh

# សេចក្តីសន្និដ្ឋាន

## 3.សេចក្តីសន្និដ្ឋាន

សៀវភៅណែនាំស្តីពីឧត្តមានុវតន៍ គឺទទួលប្រយោជន៍ពីសកម្មភាពមុនៗនៃគម្រោង BALANCE។ កញ្ចប់ការងារ 1 (ការត្រៀមរៀបចំ) បានធ្វើការវាយតម្លៃ និងប្រៀបធៀបការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុនៅកម្ពុជា និងបានផ្តល់ជាសាវតារល្អមួយ ដើម្បីកំណត់ពីឧត្តមានុវត្តន៍នៅក្នុងផ្នែកនេះ។ កញ្ចប់ការងារ 2 (ការអភិវឌ្ឍសមត្ថភាព) បានបង្កើនចំណេះដឹងរបស់ដៃគូកម្ពុជា ហើយទំនាក់ទំនងជាមួយដៃគូសហភាពអឺរ៉ុប បានផ្តល់ជាវិធីសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ ដោយអនុញ្ញាតឱ្យមានការបង្កើតប្រភេទនៃឧត្តមានុវត្តន៍ខុសៗគ្នា។ ប្រភេទទាំងនោះរួមមាន៖ 1) ការគ្រប់គ្រងហិរញ្ញវត្ថុមានលក្ខណៈជាប្រព័ន្ធនាំទៅរកលទ្ធផលដែលមានតម្លាភាព និងផលិតភាព 2) ការពង្រឹង គុណភាពការអប់រំនិស្សិតតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន 3) ការគ្រប់គ្រងហិរញ្ញវត្ថុ ប្រាក់រង្វាន់លើកទឹកចិត្ត និងផលិតភាព 4) ការគ្រប់គ្រងហិរញ្ញវត្ថុជាមួយប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ការជំរុញការលើក ទឹកចិត្ត និងសកម្មភាពបំពេញការងារ 5) តួនាទី ទំនួលខុសត្រូវ ប្រតិភូកម្ម និងរចនាសម្ព័ន្ធនៃការធ្វើសេចក្តីសម្រេចចិត្ត គ្រោងប្រាក់រង្វាន់លើកទឹកចិត្ត។

សៀវភៅណែនាំស្តីពីឧត្តមានុវត្តន៍នេះ នឹងត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា និងបង្ហាញនៅក្នុងសន្និសីទជាតិ ដោយមានវត្តមានសាកលវិទ្យាល័យក្នុងស្រុកជាច្រើន។ សៀវភៅណែនាំនេះ មានគោលដៅមិនត្រឹមតែទៅលើអ្នកគ្រប់គ្រងហិរញ្ញវត្ថុនៅគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាប៉ុណ្ណោះទេ តែក៏មានគោលដៅសម្រាប់តួអង្គផ្សេងទៀតដែលចាប់អារម្មណ៍ក្នុងការធ្វើទំនើបកម្មប្រព័ន្ធអប់រំឧត្តមសិក្សាផងដែរ។

កាន់តែពិសេសនោះគឺ សមាគមនៃគម្រោង BALANCE មានគោលដៅទីមួយ ធ្វើឱ្យសៀវភៅណែនាំនេះ លើកកម្ពស់ការយល់ដឹងអំពីការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ។ ទីពីរ យើងរំពឹងថានឹងបានចូលរួមចំណែកដើម្បីបង្កើនប្រសិទ្ធភាព ផលិតភាព និងតម្លាភាពនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៃប្រព័ន្ធឧត្តមសិក្សាកម្ពុជា។

របាយការណ៍បច្ចុប្បន្ននេះ បង្ហាញពីលទ្ធផលគន្លឹះទទួលបានពីកម្មវិធី Erasmus+ នៃគម្រោង BALANCE – *"ឆ្ពោះទៅកាន់ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយចីរភាពនៃសាកលវិទ្យាល័យនៅកម្ពុជា"* ដែលដំណើរការពីខែមករា ឆ្នាំ2019 ដល់ខែមករា ឆ្នាំ2023។

កម្មវត្ថុជារួមនៃគម្រោងនេះ គឺដើម្បីពង្រឹងស្វ័យភាពហិរញ្ញវត្ថុ និងគណនេយ្យភាពនៃគ្រឹះស្ថានឧត្តមសិក្សានៅក្នុងប្រទេសកម្ពុជា តាមរយៈការធ្វើទំនើបកម្មនៃការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ និងក្របខណ្ឌផ្លូវច្បាប់។

របាយការណ៍នេះបង្ហាញបណ្តុំនៃឧត្តមានុវត្តន៍នៃគំនិតផ្តួចផ្តើមធ្វើទំនើបកម្ម ដែលធ្វើឡើងនៅក្នុងសហភាពអឺរ៉ុប និងប្រទេសកម្ពុជា ដោយរួមចំណែកដល់សាមគ្គីភាពនៃការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា។

https://www.balance-project.eu/

Co-funded by the Erasmus+ Programme of the European Union

Balance

Towards Sustainable Financial Management of Cambodian Universities

# របាយការណ៍

## ការណែនាំស្តីពីឧត្តមានុវត្តន៍សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ នៅតាមគ្រឹះស្ថានឧត្តមសិក្សា៖ សហភាពអឺរ៉ុប និងកម្ពុជា

Co-funded by the Erasmus+ Programme of the European Union